# សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច

**Université Royale de Droit et des Sciences Economiques**

**Royal university of Law and Economics**


## សារណាបញ្ចប់ការសិក្សា

# ការទទួលខុសត្រូវចំពោះ
# អំពើអនីត្យានុកូលរបស់អ្នកដទៃ

ស្រាវជ្រាវចាប់ពីថ្ងៃទី០៨ ខែមេសា ឆ្នាំ២០២៤ ដល់ថ្ងៃទី១០ ខែសីហា ឆ្នាំ២០២៤


| | |
|---|---|
| ស្រាវជ្រាវដោយ | ណែនាំដោយ |
| និស្សិតឈ្មោះ **កញ្ញា ធឿន សុវណ្ណរីសា** | **លោកស្រី ឃឹម ម៉ាណែត** |
| **កញ្ញា ម៉ក់ ចន្ទ្រា** | |


| | | | |
|---|---|---|---|
| ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ** | | ឆ្នាំចូលសិក្សា | ២០២០ |
| ជំនាន់ទី២៤ | | ឆ្នាំសរសេរសារណា | ២០២៤ |

**សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច**

**Université Royale de Droit et des Sciences Economiques**

**Royal university of Law and Economics**


# សារណាបញ្ចប់ការសិក្សា

# ការទទួលខុសត្រូវចំពោះ អំពើអនីត្យានុកូលរបស់អ្នកដទៃ

ស្រាវជ្រាវចាប់ពីថ្ងៃទី០៨ ខែមេសា ឆ្នាំ២០២៤ ដល់ថ្ងៃទី១០ ខែសីហា ឆ្នាំ២០២៤


ស្រាវជ្រាវដោយ

និស្សិតឈ្មោះ **កញ្ញា ខឿន សុវណ្ណារីសា**

**កញ្ញា ម៉ក់ ចន្ទ្រា**

ណែនាំដោយ

**លោកស្រី ឃឹម ម៉ាណែត**


ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ**

ជំនាន់ទី២៤

ឆ្នាំចូលសិក្សា ២០២០

ឆ្នាំសរសេរសារណា ២០២៤

# សេចក្តីថ្លែងអំណរគុណ

នាងខ្ញុំឈ្មោះ ធឿន សុវណ្ណរីសា និងនាងខ្ញុំឈ្មោះ ម៉ក់ ចន្ទ្រា ជានិស្សិតបរិញ្ញាបត្រផ្នែកនីតិសាស្ត្រនៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ចជំនាន់ទី២៤ ឆ្នាំសិក្សា២០២០-២០២៤។

ជាបឋមនាងខ្ញុំទាំងពីរ សូមលំឱនកាយវាចាចិត្តដើម្បីសម្តែងការគោរព ការដឹងគុណ និងកតញ្ញូតាធម៌ យ៉ាងជ្រាលជ្រៅបំផុតជូនចំពោះអ្នកមានគុណទាំងទ្វេគឺ **លោកឪពុក និងអ្នកម្តាយ** ដែលបានផ្តល់កំណើត ខិតខំប្រឹងប្រែងចិញ្ចឹមបីបាច់ថែរក្សាតាំងពីតូចក្រូចឆ្មារហូតដល់ធំធាត់ពេញវ័យ ព្រមទាំងផ្តល់នូវភាពកក់ក្តៅ សេចក្តីស្រឡាញ់ និងការអប់រំទូន្មានប្រៀនប្រដៅកូនៗប្រកបដោយព្រហ្មវិហារធម៌ ព្រមទាំងជម្រុញ និងលើកទឹកចិត្តក្នុងការបញ្ជូនកូនៗទៅទទួលការអប់រំ។ មិនតែប៉ុណ្ណោះ លោកទាំងពីរបានផ្តល់នូវការផ្គត់ផ្គង់ថវិការ និងសិក្ខាបករណ៍ចាប់តាំងពីកម្រិតបឋមសិក្សា មធ្យមសិក្សា រហូតដល់ថ្នាក់បរិញ្ញាបត្រធ្វើឱ្យកូនចងចាំជានិច្ចដោយមិនអាចបំភ្លេចបាន។

សូមគោរពថ្លែងអរគុណចំពោះ **ឯកឧត្តមសាស្ត្រាចារ្យបណ្ឌិតសាកលវិទ្យាធិការ សាកលវិទ្យាធិការរង គណៈគ្រប់គ្រង ព្រមទាំងលោក លោកស្រីសាស្ត្រាចារ្យ** ទាំងអស់នៅក្នុងសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ដែលបានបង្ហាត់បង្រៀន អប់រំទូន្មាន លះបង់ពេលវេលា ព្រមទាំងកម្លាំងកាយ កម្លាំងចិត្តដល់ខ្ញុំទាំងពីរក្នុងរយៈពេលបួនឆ្នាំកន្លងមកដើម្បីឱ្យ នាងខ្ញុំទាំងពីរទទួលបាននូវចំណេះដឹងផ្នែកនីតិសាស្ត្រ លើបញ្ហានានាដែលពាក់ព័ន្ធទៅនឹងច្បាប់ជាតិ ព្រមទាំងច្បាប់អន្តរជាតិថែមទៀតផង។

ជាពិសេសសូមថ្លែងអំណរគុណចំពោះ **លោកស្រី ឃឹម ម៉ាណែត** ដែលជាគ្រូណែនាំដើម្បីធ្វើឱ្យមាននូវដំណើរការនៃការតាក់តែង កិច្ចការស្រាវជ្រាវនេះឡើងប្រកបដោយភាពជោគជ័យ។ ជាពិសេសទៀតនោះគាត់បានចំណាយកម្លាំងកាយកម្លាំងចិត្ត និងពេលវេលាដ៏មានតម្លៃក្នុងការប្រឹងប្រែងពន្យល់ណែនាំតម្រង់ទិសផ្តល់ឯកសារពាក់ព័ន្ធ អនុសាសន៍ល្អៗ និងជួយកែលម្អចំណុចខ្វះខាតទាំងឡាយដើម្បីធ្វើយ៉ាងណាឱ្យកិច្ចការស្រាវជ្រាវមួយនេះ បានទទួលនូវលទ្ធផលល្អ និងត្រឹមត្រូវ។

ជាចុងក្រោយក៏សូមថ្លែងអំណរគុណ និងសូមប្រសិទ្ធិពរជ័យដល់វត្ថុស័ក្តសិទ្ធិក្នុងលោកសូមជួយថែរក្សាដល់លោកទាំងអស់ដែលបានរៀបរាប់ខាងលើ ជួបតែពុទ្ធពរទាំងបួនប្រការគឺ **អាយុ វណ្ណៈ សុខៈ ពលៈ** កុំបីឃ្លៀងឃ្លាតឡើយ។

# អារម្ភកថា

ក្រោយពីឆ្លងកាត់ការសិក្សាអស់រយៈកាលជិត៤ឆ្នាំកន្លងទៅ ក្នុងនាមជានិស្សិតថ្នាក់បរិញ្ញាបត្រនីតិសាស្ត្រនៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច និងក្រោមការដឹកនាំបង្ហាត់បង្រៀនពីសំណាក់លោក លោកស្រីសាស្ត្រាចារ្យមានជំនាញជាច្រើន នាងខ្ញុំទាំងពីរនាក់ទទួលបាននូវចំណេះវិជ្ជាដ៏ល្អទាក់ទងនឹងវិស័យច្បាប់។ ដើម្បីស្របទៅតាមកម្មវិធីសិក្សារបស់សាកលវិទ្យាល័យ នាងខ្ញុំទាំងពីរបានធ្វើការសម្រេចចិត្តរួមគ្នាជ្រើសយកប្រធានបទ **ការទទួលខុសត្រូវចំពោះអំពើអនីត្យានុកូលរបស់អ្នកដទៃ** ដើម្បីសរសេរជាសារណាបញ្ចប់ការសិក្សា។

ដើម្បីរៀបចំចងក្រងជាប្រធានបទនេះឡើងនាងខ្ញុំទាំងពីរបានខិតខំស្វែងរក សិក្សាស្រាវជ្រាវគ្រប់ឯកសារ គតិយុត្តដែលពាក់ពន្ធ័ជាមួយប្រធាននេះ និងទទួលបានការជួយជ្រោមជ្រែង ការពន្យល់ណែនាំពី **អ្នកគ្រូ ឃឹម ម៉ាណែត** ផងដែរ។ នាងខ្ញុំទាំងពីរសង្ឃឹមថា ស្នាដៃសារណាបញ្ចប់ការសិក្សាមួយនេះនឹងអាចក្លាយជាឯកសារមួយដ៏សំខាន់ដែលជួយផ្តល់ចំណេះដឹងជាច្រើន ព្រមទាំងជំនួយស្មារតី និងជួយសម្រួលដល់អ្នកសិក្សាស្រាវជ្រាវ មិត្តអ្នកអាន និងនិស្សិតជំនាន់ក្រោយ។

ការចងក្រងជាសារណានេះឡើងប្រាកដជានឹងមានកំហុសឆ្គង ឬខ្វះចន្លោះត្រង់ចំនុចណាមួយជាមិនខាន។ ប៉ុន្តែនាងខ្ញុំសង្ឃឹមថា រាល់កំហុសឆ្គងទាំងប៉ុន្មានពិតជាទទួលបានការអភ័យទោសពីសំណាក់លោកសាស្ត្រាចារ្យ មិត្តនិស្សិត អ្នកអានជាពុំខាន ។

ជាទីបញ្ចប់ នាងខ្ញុំទាំងពីរនាក់រង់ចាំទទួលនូវការរិះគន់ដើម្បីស្ថាបនាពីសំណាក់ ឯកឧត្តម លោកជំទាវ លោក លោកស្រី សាស្ត្រចារ្យ មិត្តអ្នកអាន និងនិស្សិតទាំងអស់ដោយក្តីសោមនស្សរីករាយ។

# មាតិកា


**សេចក្តីផ្តើម** ........ ១


## ជំពូកទី១

## ទ្រឹស្តីទូទៅនៃអំពើអនីត្យានុកូល


**១.១. សញ្ញាណទូទៅនៃអំពើអនីត្យានុកូល** ........ ៤

**១.២. លក្ខខណ្ឌនៃអំពើអនីត្យានុកូល** ........ ៥

១.២.១. ភាពខុសច្បាប់ ឬបំពានផលប្រយោជន៍អ្នកដទៃ ........ ៦

១.២.២. កំហុស ........ ៧

១.២.២.១. កំហុសចេតនា ........ ៨

១.២.២.២. កំហុសអចេតនា ........ ៨

១.២.៣. ព្យសនកម្ម ឬការខូចខាត ........ ៩

១.២.៣.១. ព្យសនកម្មខាងសម្ភារៈ ........ ៩

១.២.៣.២. ព្យសនកម្មខាងផ្លូវចិត្ត ........ ៩

១.២.៣.៣. ព្យសនកម្មខាងរូបកាយ ........ ១០

១.២.៤. ទំនាក់ទំនងរវាងអំពើ និងការខូតខាត ........ ១០

**១.៣. សមត្ថភាពទទួលខុសត្រូវ** ........ ១១

១.៣.១. អនីតិជន ........ ១១

១.៣.២. ជនមានវិបត្តិបញ្ញាស្មារតី ........ ១២

១.៣.៣. នីតិជន ........ ១២

**១.៤. មូលហេតុនៃការរួចផុតពីការទទួលខុសត្រូវ** ........ ១២

១.៤.១. ការការពារជាធម្មានុរូប ........ ១៣

១.៤.២. ស្ថានភាពចាំបាច់ ........ ១៣

១.៤.៣. ការយល់ព្រម ឬការទទួលយកគ្រោះថ្នាក់ពីជនរងគ្រោះ ........ ១៤

## ជំពូកទី២

## ការទទួលខុសត្រូវចំពោះអំពើរបស់អ្នកដទៃ

**២.១. ការទទួលខុសត្រូវរបស់អ្នកមានករណីយកិច្ចត្រួតពិនិត្យ** ...................... ១៥

២.១.១. អនីតិជនអាយុក្រោម ១៤ឆ្នាំ...................... ១៥

២.១.២. អនីតិជនចាប់ពីអាយុ ១៤ឆ្នាំ ដល់ក្រោម ១៨ឆ្នាំ...................... ១៦

២.១.៣. ជនមានវិបត្តិផ្នែកស្មារតី...................... ១៨

**២.២. ការទទួលខុសត្រូវរបស់និយោជក**...................... ១៩

២.២.១. លក្ខខណ្ឌក្នុងការទទួលខុសត្រូវ...................... ២០

២.២.២. ការទទួលខុសត្រូវ ...................... ២១

២.២.៣. ការរួចផុតពីការទទួលខុសត្រូវ ...................... ២២

២.២.៤. ការទាមទារសំណងពីនិយោជិត...................... ២៣

**២.៣. អំពើអនីត្យានុកូលរបស់នីតិបុគ្គល** ...................... ២៤

២.៣.១. លក្ខខណ្ឌក្នុងការទទួលខុសត្រូវ...................... ២៤

២.៣.១.១. នីតិបុគ្គល...................... ២៤

២.៣.១.២. អ្នកតំណាង ឬអភិបាល ...................... ២៥

២.៣.២. ការទទួលខុសត្រូវ...................... ២៦

២.៣.២.១. ការទទួលខុសត្រូវរបស់នីតិបុគ្គល ...................... ២៦

២.៣.២.២. ការទទួលខុសត្រូវរបស់អ្នកតំណាង ឬអភិបាល ...................... ២៧

២.៣.៣. ការទាមទារសំណងត្រឡប់មកវិញ...................... ២៧

**២.៤. អំពើអនីត្យានុកូលរបស់មន្ត្រីរាជការ** ...................... ២៨

២.៤.១. លក្ខខណ្ឌក្នុងការទទួលខុសត្រូវ...................... ២៩

២.៤.២. ការទទួលខុសត្រូវរបស់មន្ត្រីរាជការ...................... ២៩

២.៤.៣. ការទាមទារសំណង...................... ៣០

## ជំពូកទី៣

## ការជួសជុលព្យសនកម្ម

**៣.១. ការគណនាការខូចខាត** ............ ៣១

៣.១.១. ការខូចខាតជាទ្រព្យសម្បត្តិ ............ ៣១

៣.១.២. ការខូចខាតសតិអារម្មណ៍ ............ ៣១

៣.១.៣. ការខូចខាតលើរូបកាយ ............ ៣២

៣.១.៤. ការបំពានលើជីវិត ............ ៣២

**៣.២. គោលការណ៍នៃការសងការខូចខាត** ............ ៣៣

៣.២.១. ការសងការខូចខាតជាប្រាក់ ............ ៣៣

៣.២.២. ការទាមទារឲ្យធ្វើបដិទាន ............ ៣៤

៣.២.៣. ការហាមឃាត់មិនឲ្យធ្វើសកម្មភាពជាក់ណាត់ ............ ៣៤

**៣.៣. ការបន្ថយសំណងនៃការខូចខាត** ............ ៣៤

៣.៣.១. ការទូទាត់ប្រាក់ចំណេញ និងខាត ............ ៣៥

៣.៣.២. ការទូទាត់កំហុស ............ ៣៥

**៣.៤. អាជ្ញាយុកាលនៃការរំលត់សិទ្ធិទាមទារ** ............ ៣៦

**សេចក្ដីសន្និដ្ឋាន** ............ ៣៧

**អនុសាសន៍** ............ ៣៨

**ឯកសារយោង**

**ឧបសម្ព័ន្ធ**

# សេចក្ដីផ្ដើម

# សេចក្ដីផ្ដើម

## ១. លំនាំបញ្ហានៃការស្រាវជ្រាវ

នៅក្នុងសង្គមរស់នៅរបស់មនុស្ស ចាំបាច់ត្រូវមានវិធានដើម្បីធ្វើការគ្រប់គ្រងជីវភាពនៅក្នុងសង្គមធ្វើឱ្យមានសណ្ដាប់ធ្នាប់ល្អ។ កាលណាប្រទេសមួយមានរបៀបរៀបរយ មានសណ្ដាប់ធ្នាប់ល្អ ជាកត្តាដែលនាំឱ្យប្រទេសនោះមានសន្តិសុខ និងការអភិវឌ្ឍន៍។ ចំណែកនៅក្នុងប្រទេសកម្ពុជានាពេលបច្ចុប្បន្ន រដ្ឋាភិបាលបានខិតខំប្រឹងប្រែងនៅក្នុងការបង្កើតច្បាប់ សម្រាប់ជាការការពារផលប្រយោជន៍សាធារណៈ រក្សាសន្តិសុខសង្គម តាមរយៈការបង្កើតឱ្យមានក្រមព្រហ្មទណ្ឌ និងក្រមនីតិវិធីព្រហ្មទណ្ឌក្នុងគោលបំណងដាក់ទោសទណ្ឌទៅលើជនគ្រប់រូបដែលបានប្រព្រឹត្តខុសច្បាប់ ឬល្មើសច្បាប់ដែលមានចែងជាធរមាន ក្រមរដ្ឋប្បវេណី និងក្រមនីតិវិធីរដ្ឋប្បវេណី ក្នុងការផ្ដោតជាសំខាន់លើទំនាក់ទំនងរវាងបុគ្គលឯកជន និងបុគ្គលឯកជនតាមរយៈការបង្ហាញឆន្ទៈលើទំនាក់ទំនងទ្រព្យសម្បត្តិ និងទំនាក់ទំនងញាតិ។ វិធានច្បាប់ទាំងនេះបង្កើតឡើងដើម្បីថែរក្សាស្ថេរភាពរបស់សង្គមឱ្យមានសណ្ដាប់ធ្នាប់ល្អ ភាពសុខសន្តិភាពនៅក្នុងការរស់នៅប្រចាំថ្ងៃរបស់ប្រជាពលរដ្ឋ។

បន្ថែមពីនេះ នៅគន្ថីទី៥ ជំពូកទី១៦ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧ បានបញ្ញត្តិអំពី **អំពើអនីត្យានុកូល**។ ដែលអំពើអនីត្យានុកូល គឺជាបញ្ហាដែលកើតឡើងជាច្រើន នៅក្នុងជីវភាពរស់របស់មនុស្សក្នុងសង្គម។ អំពើអនីត្យានុកូល ជាអំពើរបស់មនុស្សដែលបានប្រព្រឹត្តអំពើដែលធ្វើឱ្យប៉ះពាល់ដល់ផលប្រយោជន៍របស់មនុស្សផ្សេងទៀត ហើយអ្នកដែលបានប្រព្រឹត្តអំពើនេះ ត្រូវទទួលខុសត្រូវនូវអំពើរបស់ខ្លួន។ ហើយអំពើអនីត្យានុកូលមិនត្រឹមត្រូវតែទទួលខុសត្រូវលើអំពើផ្ទាល់ខ្លួនទេ រួមមានទាំងការទទួលខុសត្រូវទៅអំពើរបស់សត្វ វត្ថុ និងការទទួលខុសត្រូវអំពើរបស់អ្នកដទៃផងដែរ។

ដោយសង្កេតឃើញថា ការទទួលខុសត្រូវលើអំពើរបស់អ្នកដទៃ មានការកើតឡើងច្រើនក្នុងសង្គមរស់នៅសព្វថ្ងៃ ប្រជាពលរដ្ឋខ្លះខ្វះនូវចំណេះដឹង ដោយពុំអាចយល់ច្បាស់អំពី អំពើអនីត្យានុកូល ក៏ដូចជាលក្ខខណ្ឌនៃការទទួលខុសត្រូវចំពោះអំពើអនីត្យានុកូលមានភាពស្មុគស្មាញ។ ទើបក្រុមនាងខ្ញុំបានសម្រេចចិត្តស្រាវជ្រាវ និងចងក្រងអត្ថបទទាក់ទងការទទួលខុសត្រូវនូវអំពើអនីត្យានុកូលរបស់អ្នកដទៃ ដែលជាផ្នែកមួយនៃអំពើអនីត្យានុកូល ដើម្បីជាជំនួយស្មារតីសម្រាប់ការសិក្សា និងស្រាវជ្រាវបន្ថែមទៀត។

## ២. ចំណោទបញ្ហានៃការស្រាវជ្រាវ

យោងទៅតាមការសិក្សា និងស្រាវជ្រាវកន្លងមកដើម្បីឱ្យយល់កាន់តែច្បាស់ទាក់ទងទៅនឹងការទទួលខុសត្រូវអំពើអនីត្យានុកូលរបស់ដទៃ យើងខ្ញុំបានកំណត់ចេញជាបញ្ហាគតិយុត្ត មួយចំនួនថា៖

- តើការទទួលខុសត្រូវអំពើអនីត្យានុកូលរបស់អ្នកដទៃ គឺជាអ្វី?
- តើការទទួលខុសត្រូវអំពើអនីត្យានុកូលរបស់អ្នកដទៃ មានអ្វីខ្លះ?

- តើបុគ្គលបែបណាដែលត្រូវទទួលខុសត្រូវអំពើរបស់អ្នកដទៃ?
- តើលក្ខខណ្ឌអ្វីខ្លះដែលនាំឱ្យមានការទទួលខុសត្រូវ?

## ៣. គោលបំណងនៃការស្រាវជ្រាវ

នៅក្នុងការស្រាវជ្រាវលើប្រធានបទ **ការទទួលខុសត្រូវចំពោះអំពើអនីត្យានុកូលរបស់អ្នកដទៃ** នាងខ្ញុំទាំងពីរមានគោលបំណងយល់ដឹងឱ្យកាន់តែច្បាស់អំពីការទទួលខុសត្រូវអំពើរបស់អ្នកដទៃ លក្ខខណ្ឌដែលបណ្តាលឱ្យមានការទទួលខុសត្រូវ ហើយបុគ្គលណាខ្លះដែលមានករណីយកិច្ចក្នុងការទទួលខុសត្រូវ។

## ៤. ទំហំ និងដែនកំណត់នៃការស្រាវជ្រាវ

ប្រធានបទ **ការទទួលខុសត្រូវចំពោះអំពើអនីត្យានុកូលរបស់អ្នកដទៃ** ដែលយើងបានស្រាវជ្រាវ និងលើកយកមកបកស្រាយនេះ គឺយើងផ្តោតទៅលើការទទួលខុសត្រូវអំពើរបស់អ្នកដទៃ នៅក្នុងប្រទេសកម្ពុជាតែប៉ុណ្ណោះ។ ម្យ៉ាងទៀតយើងខ្ញុំសិក្សាស្រាវជ្រាវដោយធ្វើការផ្អែកទៅលើលិខិតបទដ្ឋានគតិយុត្តមួយចំនួនដែលមានចែងជាធរមាននៅក្នុងព្រះរាជាណាចក្រកម្ពុជា ហើយមិនពាក់ព័ន្ធទៅនឹងការទទួលខុសត្រូវលើអំពើរបស់អ្នកដទៃដែលមាននៅក្នុងបណ្តាប្រទេសផ្សេងៗនោះឡើយ។

## ៥. វិធីសាស្ត្រស្រាវជ្រាវ

សារណានេះ គឺត្រូវបានធ្វើការសិក្សាស្រាវជ្រាវ និងធ្វើការរៀបរៀងឡើងដោយប្រើប្រាស់នូវ វិធីសាស្ត្របែបពិពណ៌នា និងវិភាគដោយលើកយកជាឧទាហរណ៍មួយចំនួនមកធ្វើការបង្ហាញ ។ យើងខ្ញុំបានធ្វើការប្រមូលនូវព័ត៌មានទាំងឡាយ ព្រមទាំងឯកសារពាក់ព័ន្ធទៅនឹងប្រធានបទនៃសារណានេះ ដើម្បីធានានូវភាពត្រឹមត្រូវប្រាកដប្រជា និងប្រសិទ្ធិភាពកាន់តែប្រសើរឡើង ។ ហើយព័ត៌មានទាំងអស់នេះត្រូវបានដកស្រង់ចេញពីប្រភពមួយច្បាស់លាស់ដូចជា លិខិតបទដ្ឋានគតិយុត្តរបស់ព្រះរាជាណាចក្រកម្ពុជា សៀវភៅដែលសរសេរដោយអ្នកមានជំនាញខាងវិស័យច្បាប់ សៀវភៅមេរៀនរបស់សាស្ត្រាចារ្យផ្សេងៗផងដែរ ។

## ៦. សារៈសំខាន់នៃការស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវប្រធានបទស្តី **ការទទួលខុសត្រូវចំពោះអំពើអនីត្យានុកូលរបស់អ្នកដទៃ** មានបំណងផ្តល់នូវពុទ្ធិដល់មិត្តនិស្សិត មិត្តអ្នកអាន អ្នកសិក្សាស្រាវជ្រាវ និងសាធារណជនទាំងអស់ឱ្យយល់ដឹងកាន់តែស៊ីជម្រៅអំពី អំពើអនីត្យានុកូល លក្ខខណ្ឌដែលនាំឱ្យមានការទទួលខុសត្រូវអំពើរបស់អ្នកដទៃ ដើម្បីជាទុនមួយក្នុងការយល់ដឹងដ៏មានសារៈសំខាន់សម្រាប់ជាប្រយោជន៍ដល់ការស្វែងយល់នូវចំណុចមូលដ្ឋានសំខាន់ៗ នៃការទទួលខុសត្រូវលើការខូចខាតដែលកើតចេញពីអំពើរបស់អ្នកដទៃ។

## ៧. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ

យោងទៅតាមបញ្ហាគតិយុត្ត ដែលបានលើកឡើងខាងលើ និងឆ្លងតាមរយៈការស្រាវជ្រាវទាក់ទងទៅនឹងប្រធានបទរយៈពេលកន្លងមកនេះ យើងខ្ញុំបានបែងចែកចេញប្រធានបទ **ការទទួលខុសត្រូវចំពោះអំពើអនីត្យានុកូលរបស់អ្នកដទៃ** ជា ៣ជំពូករួមមាន៖

**ជំពូកទី១៖ ទ្រឹស្តីទូទៅនៃអំពើអនីត្យានុកូល**

**ជំពូកទី២៖ ការទទួលខុសត្រូវចំពោះអំពើរបស់អ្នកដទៃ**

**ជំពូកទី៣៖ ការជួសជុលព្យសនកម្ម**

# ជំពូកទី១
# ទ្រឹស្តីទូទៅនៃអំពើអនីត្យានុកូល

# ជំពូកទី១
# ទ្រឹស្តីទូទៅនៃអំពើអនីត្យានុកូល

## ១.១. សញ្ញាណទូទៅនៃអំពើអនីត្យានុកូល

អំពើអនីត្យានុកូល គឺជាអំពើបំពារបំពានដោយខុសច្បាប់នូវសិទ្ធិ ឬផលប្រយោជន៍របស់អ្នកដទៃដោយកំហុសចេតនា ឬដោយកំហុសអចេតនា ហើយជនដែលបានប្រព្រឹត្តអំពើត្រូវទទួលខុសត្រូវក្នុងការសងការខូចខាតដែលកើតឡើងដោយសារអំពើនោះ។[1] ដូច្នេះបុគ្គលដែលមានសិទ្ធិ ឬផលប្រយោជន៍របស់ខ្លួនដែលត្រូវបានគេរំលោភបំពានមានសិទ្ធិទាមទារនូវសំណងនៃការខូចខាត។ ការនាំឱ្យមានការទទួលខុសត្រូវក្នុងអំពើអនីត្យានុកូលនេះដោយសារគោលការណ៍ទូទៅនៃការទទួលខុសត្រូវដោយមានកំហុស។ ដូច្នេះហើយ បើអ្នកប្រព្រឹត្តមិនបានប្រព្រឹត្តកំហុសទេ នោះជននោះមិនទទួលខុសត្រូវឡើយ។ តែក្នុងករណីខ្លះ អត្ថិភាពនៃកំហុសមិនមែនជាលក្ខខណ្ឌចាំបាច់ដែលនាំឱ្យមានការទទួលខុសត្រូវនោះទេ។

អំពើអនីត្យានុកូល ជារបបដែលត្រូវឱ្យអ្នកប្រព្រឹត្តអំពើបំពានត្រូវតែទទួលខុសត្រូវ។ ដូចនេះយើងសូមធ្វើការបែងចែកការទទួលខុសត្រូវចំពោះអំពើអនីត្យានុកូលជា ២ប្រភេទសំខាន់ៗដូចខាងក្រោម៖

ទី១- ការទទួលខុសត្រូវដោយមានកំហុស (អំពើអនីត្យានុកូលទូទៅ) ជាគោលការណ៍នៃការទទួលខុសត្រូវដោយកំហុស។

ទី២- ការទទួលខុសត្រូវដោយគ្មានកំហុស (អំពើអនីត្យានុកូលពិសេស) ដែលអាចជាការទទួលខុសត្រូវចំពោះវត្ថុ សត្វ និងការទទួលខុសត្រូវចំពោះអំពើបំពានរបស់អ្នកដទៃ ។

ការទទួលខុសត្រូវចំពោះអំពើអនីត្យានុកូលវាប្រែប្រួលទៅតាមស្ថានភាពនៃអ្នកដែលត្រូវទទួលខុសត្រូវដែរពោល គឺអាចជាការទទួលខុសត្រូវដោយឯកឯង ឬការទទួលខុសត្រូវរួម។ គឺមានន័យថាត្រូវទទួលខុសត្រូវក្នុងការសងការខូចខាតដែលកើតឡើងដោយអំពើនោះ ឬអំពើអនីត្យានុកូលដែលត្រូវបានប្រព្រឹត្តដោយបុគ្គលច្រើនគ្នាដែលយើងហៅថាអំពើអនីត្យានុកូលរួម នោះអ្នកប្រព្រឹត្តអំពើអនីត្យានុកូលត្រូវទទួលខុសត្រូវដោយសាមគ្គី។ ហើយការខូចខាតមានច្រើនទម្រង់ទៅតាមប្រភេទនៃអំពើអនីត្យានុកូលផងដែរ។ កម្មវត្ថុនៃសំណងនៃការខូចខាតមិនត្រឹមតែមានការខូចខាតផ្នែកទ្រព្យសម្បត្តិប៉ុណ្ណោះទេ វាមានទាំងការខូចខាតខាងផ្លូវចិត្តផងដែរ។

[1] ក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧, មាត្រា ៧៤៣ វាក្យខណ្ឌទី១។

អ្នកដែលមានករណីយកិច្ចត្រួតពិនិត្យចំពោះអសមត្ថជន គឺត្រូវបានចាត់ទុកថាជាអ្នកមានករណីយកិច្ចក្នុងការទទួលខុសត្រូវនូវសំណងនៃការខូចខាតចំពោះទង្វើដែលបានបង្ករបស់អសមត្ថជន ឬជនដែលគ្មានសមត្ថភាពក្នុងការទទួលខុសត្រូវ។ ចំណែកឯ នីតិបុគ្គលក៏ត្រូវទទួលខុសត្រូវចំពោះសំណងនៃការខូចខាតលើអំពើដែលបង្កឱ្យមានការខូចខាតរបស់អភិបាលនៃនីតិបុគ្គលនោះ។ ចំពោះរដ្ឋ ឬស្ថាប័នសាធារណៈវិញគឺមានភារកិច្ចទទួលខុសត្រូវនូវសំណងនៃការខូចខាតទៅលើទង្វើដែលបង្កឱ្យមានការខូចខាតពីសំណាក់មន្ត្រីរាជការផងដែរ។ [2] បុគ្គលដែលកាន់កាប់សត្វ ក៏ត្រូវទទួលខុសត្រូវនូវការសងសំណងនៃការខូចខាតដែលបង្កមកពីសត្វចិញ្ចឹមរបស់ខ្លួនផងដែរ ។[3] លើសពីនេះទៅទៀតនៅក្នុងករណីពិសេស ដែលបានទទួលស្គាល់អំពីការទទួលខុសត្រូវដែលវាជាការទទួលខុសត្រូវចំពោះការខូចខាតបណ្តាលមកពីវត្ថុមានគ្រោះថ្នាក់ដោយវាមិនចាំបាច់ត្រូវមានលក្ខខណ្ឌកំហុស ។[4]

អំពើអនីត្យានុកូល តម្រូវឱ្យមានសងសំណងការខូចខាតខាងសេដ្ឋកិច្ច និងខាងផ្លូវចិត្តចំពោះជនរងគ្រោះដើម្បីទទួលបាននូវយុត្តិធម៌។ ការទទួលខុសត្រូវលើអំពើអនីត្យានុកូល គឺយោងទៅតាមគោលការណ៍នៃការទទួលខុសត្រូវកំហុស មានន័យថានៅក្នុងសង្គមដែលមានសេរីភាពខាងអំពើត្រូវបានធានា។ ជាគោលការណ៍បុគ្គលម្នាក់ៗមិនត្រូវទទួលខុសត្រូវនោះទេ ហើយបុគ្គលម្នាក់ៗត្រូវទទួលខុសត្រូវចំពោះលទ្ធផល ដែលនឹងកើតមានឡើងពីសកម្មភាពដែលអាចត្រូវបានព្យាករទុកជាមុនបានក្នុងការបំពាននូវសិទ្ធិ ឬផលប្រយោជន៍របស់អ្នកដទៃ។ ចំពោះសកម្មភាពដែលមិនអាចព្យាករដឹងពីលទ្ធផលនៃសកម្មភាពនោះ។ ជាទូទៅ ច្បាប់មិនតម្រូវឱ្យទទួលខុសត្រូវនោះទេ ពីព្រោះវានឹងរារាំងដល់សកម្មភាពដោយសេរីទៅវិញ ដូច្នេះគោលការណ៍នេះ គឺមិនតម្រូវឱ្យមានការទទួលខុសត្រូវទេទោះបីជាមានការខូចខាតក៏ដោយប្រសិនបើអ្នកធ្វើសកម្មភាពនោះ មិនធ្វើអំពើដោយមានកំហុសចេតនា ឬកំហុសអចេតនានោះ (ករណីលើកលែង គឺទម្រង់ពិសេស មួយចំនួននៃអំពើអនីត្យានុកូល) ។[5]

## ១.២. លក្ខខណ្ឌនៃអំពើអនីត្យានុកូល

អំពើអនីត្យានុកូល គឺជារបបនៃការទទួលខុសត្រូវរបស់អ្នកប្រព្រឹត្តអំពើបំពានណាមួយដែលត្រូវសងការខូចខាតដល់ជនរងគ្រោះដែលបង្កដោយសារអំពើនោះ។ ដើម្បីកំណត់បានថាអំពើណាមួយជាអំពើអនីត្យានុកូលបានលុះត្រាតែបំពេញតាមលក្ខខណ្ឌដូចជា ៖

[2] សេចក្តីកំណត់ចំពោះមាត្រានីមួយៗនៃក្រមរដ្ឋប្បវេណី(ភ្នំពេញ៖ក្រសួងយុត្តិធម៌,២០១០), ភាគ ៣, ទំព័រ ១៨០។

[3] ក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧, មាត្រា ៧៥០។

[4] សេចក្តីកំណត់ចំពោះមាត្រានីមួយៗនៃក្រមរដ្ឋប្បវេណី(ភ្នំពេញ៖ក្រសួងយុត្តិធម៌,២០១០), ភាគ ៣, ទំព័រ ១៨០។

[5] សេចក្តីពន្យល់ក្រមរដ្ឋប្បវេណី, (ភ្នំពេញ៖សាលាភូមិន្ទរដ្ឋបាល,២០១២) ភាគ ៤, ទំព័រ ១៨។

- ភាពខុសច្បាប់ ឬបំពានផលប្រយោជន៍អ្នកដទៃ
- អំពើបំពានដោយកំហុស
- ការខូចខាត
- ទំនាក់ទំនងរវាងហេតុ និងផល។[6]

### ១.២.១. ភាពខុសច្បាប់ ឬបំពានផលប្រយោជន៍អ្នកដទៃ

ការបំពានដោយខុសច្បាប់នូវសិទ្ធិ ឬផលប្រយោជន៍ត្រឹមត្រូវរបស់អ្នកដទៃដោយកំហុសចេតនាក្តី ឬកំហុសអចេតនាក្តី គឺជាអំពើផ្ទុយច្បាប់។ ដោយផ្អែកតាមមាត្រា ៧៤៣ កថាខណ្ឌទី១ នៃក្រមរដ្ឋប្បវេណី បានចែងថា " បុគ្គលដែលបំពានដោយខុសច្បាប់នូវសិទ្ធិ ឬផលប្រយោជន៍របស់ជនដទៃ ដោយកំហុសចេតនា ឬដោយកំហុសអចេតនា ត្រូវទទួលខុសត្រូវក្នុងការសងការខូចខាតដែលកើតឡើងដោយអំពើនោះ " ។ ការបំពានដោយខុសច្បាប់មានន័យថា មិនត្រឹមតែបំពានទៅលើច្បាប់ព្រហ្មទណ្ឌនិងច្បាប់ផ្សេងៗប៉ុណ្ណោះទេប៉ុន្តែថែមទាំងអំពើផ្ទុយនឹងវិន័យសង្គម។ ហើយអំពើបំពានត្រូវបានបែកចែកជា៤ គឺ៖[7]

- **អំពើបំពានលើបញ្ញត្តិច្បាប់៖** គ្រប់អំពើរំលោភបំពានលើសិទ្ធិ និងប្រយោជន៍របស់ជនដទៃដែលត្រូវបានកំណត់ការពារដោយច្បាប់ ទោះបីជាច្បាប់ព្រហ្មទណ្ឌច្បាប់រដ្ឋប្បវេណី ឬច្បាប់ផ្សេងទៀតដែលបានបញ្ញត្តិការពារនូវប្រយោជន៍របស់ជនដទៃក្តី ដូចជាការផ្សាយព័ត៌មានមិនពិតដែលធ្វើឱ្យប៉ះពាល់ដល់កិត្តិយស សេចក្តីថ្លៃថ្នូររបស់បុគ្គលនោះជាបទល្មើសដែលត្រូវបានច្បាប់ព្រហ្មទណ្ឌបញ្ញត្តិ។ អាស្រ័យហេតុនេះជនដែលបានបំពានត្រូវទទួលខុសត្រូវសងការខូចខាតដែល បង្កឡើងដោយសារអំពើរបស់ខ្លួន។ត្រូវបានរាប់បញ្ចូលទាំងអំពើបំពានទៅលើបញ្ញត្តិ ច្បាប់ដែលមានលក្ខណៈចាប់បង្ខំ ដើម្បីការពារប្រយោជន៍របស់បណ្តាជនដទៃផងដែរ។
- **អំពើបំពានលើសណ្តាប់ធ្នាប់សាធារណៈ និងសីលធម៌សង្គម៖** អំពើបំពានលើសណ្តាប់ធ្នាប់ និងសីលធម៌សង្គមដែលបានបង្កឱ្យមានការអន្តរាយនាំឱ្យកើតនូវការទទួលខុសត្រូវ និងសងការខូចខាតនោះ ទោះបីជាអំពើនោះបានបំពានលើបញ្ញត្តិច្បាប់ ឬក្នុងករណីខ្លះទៀតអំពើនេះមានបញ្ញត្តិច្បាស់លាស់នៅក្នុងបញ្ញត្តិច្បាប់ជាក់ស្តែងណាមួយក៏ដោយ ។

[6] ក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧, មាត្រា ៧៤៣។

[7] ឯកឧត្តម ហ៊ី សោភា, មេរៀនស្តីពីអំពើអនីត្យានុកូល, ទំព័រ ៧៣។

- **អំពើបំពានដោយកំហុសការប្រើប្រាស់សិទ្ធិដោយបំពាន៖** នៅក្នុងទស្សនៈរបស់អ្នកច្បាប់កាលពីសម័យមុន មិនទទួលស្គាល់នូវចរិតផ្ទុយច្បាប់នៃសកម្មភាពអនុវត្តសិទ្ធិនោះឡើយ។ ប៉ុន្តែនាពេលបច្ចុប្បន្នទស្សនៈនេះត្រូវបានលុបចោលហើយទទួលស្គាល់នូវលក្ខណៈផ្ទុយច្បាប់នៃការអនុវត្តសិទ្ធិដែលពុំសមស្របផលប្រយោជន៍សាធារណៈ និងហាមឃាត់ការប្រើប្រាស់សិទ្ធិដោយបំពាននេះទៀតផង។
- **ការអន្តរាយដល់តតិយជនបង្កឡើងដោយវិការៈនៃវត្ថុ៖** បណ្តាប្រទេសដែលប្រើប្រាស់ប្រព័ន្ធនីតិរួមបានបញ្ញត្តិអំពីការទទួលខុសត្រូវរបស់ផលិតករ ចំពោះវត្ថុដែលមានគ្រោះថ្នាក់បង្កឱ្យមានការអន្តរាយដល់តតិយជនដូចជា គ្រឿងចក្រ ឧបករណ៍ប្រើប្រាស់ ឱសថ ម្ហូបអាហារមិនធានាគុណភាពសុវត្ថិភាព ដែលបង្កឱ្យមានការអន្តរាយដល់អ្នកប្រើប្រាស់ជាដើម។

### ១.២.២. កំហុស

ដើម្បីកំណត់អំពីការទទួលខុសត្រូវចំពោះអំពើអនីត្យានុកូល គឺទាមទារឱ្យមានកំហុសនៅពេលដែលមានការអន្តរាយកើតឡើង។ កំហុស គឺជាស្ថានភាពផ្លូវចិត្តរបស់មនុស្សដែលអាចធ្វើជាម្ចាស់នៃខ្លួន ពោលគឺអាចយល់ដឹងបាននូវអំពើ និងលទ្ធផលដែលកើតចេញពីអំពើរបស់ខ្លួន ។[8] ហើយកំហុសក៏ជាទង្វើរបស់បុគ្គលណាម្នាក់ដែលបានប្រព្រឹត្តនូវអំពើនាំឱ្យមានព្យសនកម្មទៅលើអ្នកដទៃ ដោយស្តែងឡើងក្រោមរូបភាពជាកំហុសទាំងចេតនា ឬកំហុសអចេតនា។ អំពើដោយមានកំហុសចេតនា ឬអចេតនា សំដៅទៅលើអំពើដែលត្រូវនឹងចំណុចណាមួយដូចខាងក្រោម៖[9]

ក. ការធ្វើអំពីបំពានដោយព្យាករទុកជាមុនអំពីការកើតឡើងនៃលទ្ធផល ហើយទទួលយកការកើតឡើងនៃការលទ្ធផលនោះ។

ខ. ធ្វើអំពើដែល បើតាមការប្រក្រតី បុគ្គលដែលមានឋានៈនៃការងារ ឬបទពិសោធន៍ស្មើគ្នា នឹងអ្នកធ្វើអំពើនេះអាចព្យាករទុកជាមុនអំពីការកកើតនៃលទ្ធផលក៏ដោយ ក៏អ្នកធ្វើអំពើរនោះនៅតែពុំបានព្យាករទុកជាមុនអំពីការកើតឡើងនៃលទ្ធផលនោះដោយសារការធ្វេសប្រហែសការមិនបានប្រុងប្រយ័ត្ន ហើយទោះជាមានករណីកិច្ចជៀសវាងនូវលទ្ធផលនោះក៏ដោយក៏នៅតែប្រព្រឹត្តផ្ទុយនឹងករណីយកិច្ចនោះ។

---

[8] ឯកឧត្តម ហ៊ី សោភា, មេរៀនស្តីពីអំពើអនីត្យានុកូល, ទំព័រ ៦៤។

[9] ក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧, មាត្រា ៧៤២។

#### ១.២.២.១. កំហុសចេតនា

កំហុសចេតនា មានន័យថាការប្រព្រឹត្តអំពើអ្វីមួយដែលជននោះយល់ដឹង ឬព្យាករបានថាអំពើរបស់ខ្លួននឹងបង្កើតឱ្យមានលទ្ធផល គឺការអន្តរាយដល់ជនដទៃ ហើយខ្លួនព្រមទទួលយកការកើតឡើងនូវលទ្ធផលនោះ ទោះបីជាគោលដៅនៃអំពើមិនប្រាកដថាត្រូវបង្កឱ្យមានអន្តរាយក្តី។ កំហុសចេតនាក៏ចាត់ទុកជាកំហុសដែលចារីបង្កើតឡើងពីឆន្ទៈ ហើយចង់បង្កឱ្យមានព្យសនកម្មដល់ជនរងគ្រោះ កំហុសនេះអាចជាទង្វើបង្កជាបទល្មើសព្រហ្មទណ្ឌ ឬជាទង្វើដែលមិនត្រូវបានចាត់ទុកជាបទល្មើសព្រហ្មទណ្ឌដែរ។[10]

**ឧទាហរណ៍៖** លោក **ក** បានទៅមើលប្រដាល់នៅក្លឹបប្រដាល់មួយកន្លែងនៅចុងភូមិជាមួយលោក **ខ** ។ ដោយសារកីឡាករដែលអ្នកទាំងពីរគាំទ្រមិនដូចគ្នា ហើយលោក **ខ** បាននិយាយមើលងាយមកឱ្យកីឡាករដែលលោក **ក** គាំទ្រ ទើបបង្កើតឱ្យមានទំនាស់ពាក្យសម្តីឡើងមក។ បន្ទាប់មកលោក ក បានវាយលោក ខ បណ្តាលឱ្យរងរបួសដោយសារមានទំនាស់ពាក្យសម្តីជាមួយគ្នា។ ក្នុងករណីនេះបានបង្ហាញថា លោក **ក** មានចេតនាវាយលោក **ខ** ។

#### ១.២.២.២. កំហុសអចេតនា

កំហុសអចេតនា គឺជាអំពើដែលកើតឡើងដោយសារការធ្វេសប្រហែស មិនប្រុងប្រយ័ត្ន ដែលធ្វើឱ្យមានការខូចខាតដល់អ្នកដទៃ។ បើតាមប្រក្រតីបុគ្គលដែលមានឋានៈនៃការងារ ឬបទពិសោធន៍ ស្មើគ្នានឹងអ្នកធ្វើអំពើនោះ អាចព្យាករទុកជាមុនអំពីការកើតឡើងនៃលទ្ធផលក៏ដោយ ក៏អ្នកធ្វើអំពើនោះ នៅតែពុំបានព្យាករទុកជាមុនអំពីការកើតឡើងនៃលទ្ធផលនោះដោយសារការធ្វេសប្រហែសមិនប្រុងប្រយ័ត្ន ហើយទោះជាមានករណីយកិច្ចជៀសវាងនូវលទ្ធផលនោះក៏ដោយ ក៏នៅតែប្រព្រឹត្តផ្ទុយនឹងករណីយកិច្ចនោះ។[11]

**ឧទាហរណ៍៖** លោក **ក** បានបើកឡានទៅកន្លែងកន្លែងធ្វើការរបស់គាត់។ នៅតាមផ្លូវធ្វើដំណើរគាត់បានជួបគ្រោះថ្នាក់ចរាចរណ៍ដោយឡានរបស់គាត់បានប៉ះជាម៉ូតូរបស់អ្នកស្រី **ខ** បណ្តាលឱ្យគាត់ដួលម៉ូតូហើយរងរបួសបន្តិចបន្តួច។ គ្រោះថ្នាក់នៃកើតឡើងដោយសារតែកំឡុងពេលបើកបរ លោក **ក** បាននិយាយទូរស័ព្ទទើបមិនបានផ្តោតអារម្មណ៍ក្នុងការបើកបរដែលជាហេតុធ្វើឱ្យមានគ្រោះថ្នាក់កើតឡើង។ នេះហើយជាកំហុសអចេតនារបស់លោក **ក** ដែលមានការធ្វេសប្រហែសធ្វើឱ្យការខូចខាតចំពោះអ្នកដទៃ ហេតុនេះហើយលោក **ក** ត្រូវទទួលខុសត្រូវនូវអំពើដែលគាត់បានប្រព្រឹត្ត។

---

[10] ឯកឧត្តម ហ៊ី សោភា, មេរៀនស្តីពីអំពើអនីត្យានុកូល, ទំព័រ ៦៩។

[11] ក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧, មាត្រា ៧៤៣ ចំណុច៤។

### ១.២.៣. ព្យសនកម្ម ឬការខូចខាត

ការខូចខាត ឬព្យសនកម្ម គឺជាសេចក្ដីវិនាសអន្តរាយដែលកើតចេញពីអំពើបំពានសិទ្ធិ ឬផលប្រយោជន៍របស់ជនរងគ្រោះ។ ការខូចខាត ជាលក្ខខណ្ឌដែលសំខាន់មួយបណ្ដាលឱ្យមានការទទួលខុសត្រូវ។ ប្រសិនបើមានអំពើបំពានសិទ្ធិ ឬផលប្រយោជន៍អ្នកដទៃ តែពុំមានការខូចខាតណាមួយកើតឡើងនោះមិនមានការទទួលខុសត្រូវសងសំណងការខូចខាតកើតមានឡើយ។

ការខូចខាតបែងចែកចេញជាបីប្រភេទគឺៈ

- ការខូចខាតខាងរូបកាយ
- ការខូចខាតខាងសម្ភារៈ
- ការខូចខាតខាងសតិអារម្មណ៍។

#### ១.២.៣.១. ព្យសនកម្មខាងសម្ភារៈ

ការខូចខាតខាងសម្ភារៈ គឺជាការខូចខាតទាំងឡាយណាដែលប៉ះពាល់ដល់បេតិកភណ្ឌរបស់បុគ្គល។ ការខូចខាតខាងសម្ភារៈអាចស្ដែងឡើងក្រោមរូបភាពជា ការបែកបាក់ បាត់បង់ខូចខាតនូវវត្ថុ ប្រាក់កាស ការខកខានមិនបានចំណេញ ប្រាក់ចំណូល។ ហើយជនរងគ្រោះពីអំពើនោះ អាចទាមទារនូវសំណងតម្លៃនៃវត្ថុ ឬទ្រព្យសម្បត្តិដែលបែកបាក់ ឬសោហ៊ុយជួសជុលបាន។[12]

**ឧទាហរណ៍**ៈ លោក **ក** បានខ្ចីទូរស័ព្ទរបស់មិត្តភក្តិគាត់ដើម្បីថតរូប ដោយសារតែមានការធ្វេសប្រហែសលោក **ក** បានធ្វើឱ្យទូរស័ព្ទនៅធ្លាក់បែកអេក្រង់ទូរស័ព្ទ។ ដូច្នេះហើយលោក **ក** ទទួលខុសត្រូវនូវទង្វើរបស់គាត់ដោយផ្ដល់នូវសំណងជួសជុលការខូតខាត។

#### ១.២.៣.២. ព្យសនកម្មខាងផ្លូវចិត្ត

ការខូចខាតខាងផ្លូវចិត្ត ឬសតិអារម្មណ៍ សំដៅដល់ការខូចខាតទាំងឡាយណាដែលប៉ះពាល់ដល់ ខាងអារម្មណ៍ ប្រាជ្ញា ឬប៉ះពាល់ដល់សិទ្ធិក្រៅបេតិកភណ្ឌដូចជា កិត្តិយស ជីវភាពឯកជន ឬមនោសញ្ចេតនា។[13] នៅពេលដែលជនរងគ្រោះ ទាមទារសំណងផ្លូវចិត្តមិនតម្រូវឱ្យបង្ហាញភស្តុតាងជាក់លាក់ពីចំនួននៃសំណងនោះទេ ពីព្រោះមិនអាចទៅរួចហើយចំនួនជាក់លាក់ត្រូវកំណត់ដោយតុលាការ ប៉ុន្តែជនរងគ្រោះ ឬអ្នកមានសិទ្ធិ

---

[12] ក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧, មាត្រា ៧៥៩។

[13] សាស្ត្រាចារ្យ ញឹក វុឌ្ឍី, នីតិកាតព្វកិច្ចក្រៅកិច្ចសន្យា, ទំព័រ ១៥។

ទាមទារត្រូវបង្ហាញពីភាពឈឺចាប់ ទំនាក់ទំនងគ្រួសារ សកម្មភាពនានាដែលជាអនុស្សាវរីយ៍ជាមួយគ្នាពីមុនរូបភាព អារម្មណ៍ខ្លោចផ្សាការបាក់ទឹកចិត្ត។

**ឧទាហរណ៍៖** លោក **គ** បានបើកឡានបុកនារីម្នាក់បណ្តាលឱ្យបាត់បង់ជីវិត។ ក្នុងករណីនេះក្រុមគ្រួសារជនរងគ្រោះមានសិទ្ធិទាមទារសំណងការខូចខាតខាងសតិអារម្មណ៍ពីលោក **គ** ដោយហេតុថាមនោសញ្ចេតនា ទុក្ខព្រួយដែលបានបាត់បង់មនុស្សជាទីស្រឡាញ់។

### ១.២.៣.៣. ព្យសនកម្មខាងរូបកាយ

ព្យសនកម្មខាងរូបកាយ គឺជាការខូតខាតដែលប៉ះពាល់ដល់រូបកាយជនរងគ្រោះដូចជា ការឈឺចាប់រូបកាយ ពិការភាព ខូចសម្ផស្ស ឬរហូតដល់បាត់បង់ជីវិតជនរងគ្រោះ។[14] បើមានការបំពានលើរូបរាងកាយដោយអំពើអនីត្យានុកូល ជនរងគ្រោះអាចទាមទារសំណងនៃការខូចខាតលើទ្រព្យសម្បត្តិ និងការខូចខាតសតិអារម្មណ៍ដែលបានកើតឡើងចំពោះខ្លួន។ ការខូចខាតលើទ្រព្យសម្បត្តិត្រូវរួមបញ្ចូលទាំងសោហ៊ុយព្យាបាលដែលបានចំណាយហើយ ឬសោហ៊ុយព្យាបាលដែលប្រមាណថានឹងត្រូវចំណាយនាពេលអនាគត ប្រាក់ចំណូលដែលមិនអាចទទួលបាននៅពេលកំពុងព្យាបាល និងប្រាក់ចំណូលដែលមិនអាចទទួលបាននៅពេលអនាគតដោយសារផលវិបាកដែលបន្សល់ក្រោយពីការព្យាបាល។ [15] មាត្រាខាងលើនេះ បង្ហាញពីការខាតបង់របស់ជនរងគ្រោះផ្សេងៗនៅពេលមានព្យសនកម្ម។ នៅមានការចំណាយផ្សេងទៀតដូចជា សោហ៊ុយព្យាបាល សោហ៊ុយធ្វើដំណើរទៅមន្ទីរពេទ្យ ការចំណាយផ្សេងៗអំឡុងពេលសម្រាកនៅពេទ្យ សោហ៊ុយមើលថែរក្សារបស់គិលានុបដ្ឋាក សោហ៊ុយបុណ្យសព សោហ៊ុយព្យាបាលនានាដែលអាចកើតមានឡើងនាពេលអនាគត។

**ឧទាហរណ៍៖** លោក **ខ** បានទាស់សម្តីគ្នាជាមួយអ្នកជិតខាងរហូតឈានទៅការវាយតប់គ្នា។ លោក **ខ** បានវាយអ្នកជិតខាងរបស់គាត់បណ្តាលឱ្យបាក់ដៃម្ខាង។ ក្នុងករណីនេះ ព្យសនកម្មខាងរូបកាយគឺ ជនរងគ្រោះបានបាក់ដៃម្ខាង។

## ១.២.៤. ទំនាក់ទំនងរវាងអំពើ និងការខូតខាត

ទំនាក់ទំនងរវាងអំពើបំពារបំពាន និងការខូចខាត គឺជាទំនាក់ទំនងរវាងអំពើរបស់ចារី ដែលនាំឱ្យការខូចខាតដល់ជនរងគ្រោះ។ ការខូចខាតអាចកើតមានឡើងដោយសារអំពើបំពានរបស់អ្នកប្រព្រឹត្ត ប្រសិនបើគ្មានអំពើបំពាននេះទេ នោះការខូចខាតនឹងពុំអាចកើតមានឡើងទេ។ ចំពោះកំហុសចេតនា ឬអចេតនារបស់ចារីនេះ ទំនាក់ទំនងនៃហេតុផលរវាងអំពើរបស់អ្នកប្រព្រឹត្តអំពើបំពាន និងការកើតឡើងនៃការខូចខាត និងការខូចខាត

[14] សាស្ត្រាចារ្យ ញឹក វុធ្នី, នីតិកាតព្វកិច្ចក្រៅកិច្ចសន្យា, ទំព័រ ១៩។

[15] ក្រមរដ្ឋប្បវេណី, ឆ្នាំ ២០០៧, មាត្រា ៧៦១។

ដែលកើតមានឡើងលើជនរងគ្រោះ បុគ្គលដែលទាមទារសំណងការខូចខាតនៅត្រូវបញ្ជាក់បង្ហាញ។[16] ដូច្នោះហើយដើម្បីឱ្យជនណាម្នាក់ទទួលខុសត្រូវសងសំណងការខូចខាត លុះត្រាតែជនរងគ្រោះត្រូវបញ្ជាក់បង្ហាញពីអំពើនាំឱ្យមានការខូចខាត និងការខូចខាតដែលបានទទួលមានទំនាក់ទំនងពីហេតុទៅផលយ៉ាងពិតប្រាកដ។

**ឧទាហរណ៍៖** ជនរងគ្រោះមានរបួសបាក់ជើង ដោយសារអ្នកបើករថយន្តបើកបុកដោយសារខ្វះការប្រុងប្រយ័ត្ន ហើយជនរងគ្រោះបានប្តឹងទាមទារសំណងការខូចខាតពីអ្នកបើកបររថយន្ត។ ក្នុងករណីនេះ ជនរងគ្រោះត្រូវធ្វើការបង្ហាញភស្តុតាងថា អ្នកបើរថយន្តជាអ្នកធ្វើអោយខ្លួនមានរបួស ហើយបណ្តាលឱ្យមានការខូចខាត។

ដូចនេះ ទំនាក់ទំនងហេតុ និងផលក្នុងករណីខាងលើនេះគឺជាទំនាក់ទំនងរវាងអំពើបើកបររថយន្តបុកដោយខ្វះការប្រុងប្រយ័ត្ន និងរបួសបាក់ជើងដែលជាការខូចខាត។

## ១.៣. សមត្ថភាពទទួលខុសត្រូវ

សមត្ថភាពទទួលខុសត្រូវ គឺជាលក្ខខណ្ឌមួយដើម្បីកំណត់អំពីការទទួលខុសត្រូវអំពើអនីត្យានុកូល។ បុគ្គលដែលមានសមត្ថភាពទទួលខុសត្រូវអំពើអនីត្យានុកូល ត្រូវជាបុគ្គលដែលមានសមត្ថភាពក្នុងការយល់ដឹង និងអាចពិចារណាអំពីអំពើរបស់ខ្លួនបាន។ ចំពោះជនដែលគ្មានការយល់ដឹង និងអាចពិចារណាថា អំពើរបស់ខ្លួនត្រឹមត្រូវ ឬមិនត្រឹមត្រូវជននោះមិនទទួលខុសត្រូវចំពោះអំពើអនីត្យានុកូលរបស់ខ្លួនទេ។ ជាគោលការណ៍ក្រមរដ្ឋប្បវេណីផ្តល់នូវការការពារដល់ជនដែលមានសមត្ថភាពទាបហើយដែលមិនអាចវិនិច្ឆ័យនិងធ្វើសកម្មភាពតាមលក្ខណៈសមហេតុផលបាន។ ស្តីពីការទទួលខុសត្រូវខាងអំពើអនីត្យានុកូល អនីតិជនដែលមានអាយុក្រោម ១៤ ឆ្នាំ ឬ ជនដែលមានវិបត្តិផ្នែកបញ្ញាស្មារតី រួចផុតពីការទទួលខុសត្រូវចំពោះ អំពើអនីត្យានុកូល ។ ផ្ទុយទៅវិញ ច្បាប់តម្រូវឱ្យមានការទទួលខុសត្រូវជាពិសេសមួយទៅលើអ្នកគ្រប់គ្រងដែលជាការសង្គ្រោះមួយដល់ជនរងគ្រោះ ។[17]

### ១.៣.១. អនីតិជន

អនីតិជន សំដៅដល់ជនដែលមានអាយុក្រោម១៨ ឆ្នាំ។[18] អនីតិជនបែងចែកចេញជា២ គឺអនីតិជនក្រោម ១៤ឆ្នាំ និងអនីតិជនចាប់ពី១៤ឆ្នាំដល់ក្រោម ១៨ឆ្នាំ។

- **អនីតិជនក្រោម ១៤ឆ្នាំ៖** ជនដែលមានអាយុក្រោយ ១៤ឆ្នាំ មិនត្រូវទទួលខុសត្រូវអំពើអនីត្យានុកូលទេ។

---

[16] ក្រមរដ្ឋប្បវេណី ឆ្នាំ ២០០៧, មាត្រា ៧៤៣ វាក្យខណ្ឌទី៣។

[17] សេចក្តីពន្យល់ក្រមរដ្ឋប្បវេណី, (ភ្នំពេញ៖សាលាភូមិន្ទរដ្ឋបាល,២០១២) ភាគ ៤,ទំព័រ ២៥។

[18] ក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧, មាត្រា ១៧។

- **អនីតិជនចាប់ពី ១៤ដល់ក្រោម ១៨ឆ្នាំ៖** ត្រូវទទួលខុសត្រូវការអំពើដែលខ្លួនបានប្រព្រឹត្តដែលនាំឱ្យការខូចខាតដល់អ្នកដទៃ។ ដោយការជួសជុលការខូចខាតនេះត្រូវទទួលខុសត្រូវរួមរវាងអនីតិជន និងឪពុកម្តាយ ឬអាណាព្យាបាលនៃអនីតិជននោះ។

### ១.៣.២. ជនមានវិបត្តិបញ្ញាស្មារតី

ជនមានវិបត្តិបញ្ញាស្មារតី គឺជាបុគ្គលដែលមានសតិបញ្ញាមិនគ្រប់គ្រាន់មិនអាចបង្ហាញឆន្ទៈរបស់ខ្លួន មិនអាចយល់ដឹងអំពីសកម្មភាពរបស់ខ្លួន។ កាលបើជននោះបានប្រព្រឹត្តអំពើដែលធ្វើឱ្យប៉ះពាល់ដល់សិទ្ធិ ឬផលប្រយោជន៍អ្នកដទៃ ជននេះមិនត្រូវទទួលខុសត្រូវចំពោះអំពើអនីត្យានុកូលរបស់ខ្លួនឡើយ។

**ឧទាហរណ៍៖** លោក **ក** មានកូនប្រុសម្នាក់ដែលមានបញ្ហាផ្នែកស្មារតីតាំងពីកំណើត ហើយលោក **ក** ក៏បានយកកូនប្រុសនោះទៅព្យាបាលនៅមន្ទីរពេទ្យមួយកន្លែង ហើយលោកគ្រូពេទ្យបានបញ្ជាក់ថាជម្ងឺនេះមិនអាចព្យាបាលបានទេ។ ថ្ងៃមួយកូនរបស់លោក **ក** បានយកដុំថ្មគប់អ្នកជិតខាងបណ្តាលឱ្យបែកក្បាល។ ក្នុងអង្គហេតុនេះ ដោយសារកូនប្រុសលោក **ក** មានវិបត្តិផ្នែកស្មារតីនោះ កូនប្រុសរបស់លោក **ក** មិនត្រូវទទួលខុសត្រូវអំពើអនីត្យានុកូលរបស់ខ្លួនទេ។

### ១.៣.៣. នីតិជន

នីតិជន សំដៅដល់ជនទាំងឡាយណាដែលមានអាយុចាប់ពី ១៨ឆ្នាំឡើងទៅ។ នីតិជន ជាបុគ្គលដែលមានអាយុគ្រប់តាមច្បាប់កំណត់ ហើយមានសមត្ថភាពឯករាជ្យខាងអំពើ។ [19] នៅក្នុងន័យនេះយើងអាចនិយាយបានថា ជាជនដែលមានបញ្ញាស្មារតីនៅក្នុងការយល់ដឹង និងអាចពិចារណានូវទង្វើសកម្មភាពរបស់ខ្លួនត្រឹមត្រូវ ឬមិនត្រឹមត្រូវ។ ហើយបុគ្គលទាំងនេះត្រូវទទួលខុសត្រូវនូវអំពើអនីត្យានុកូលរបស់ខ្លួនដែលធ្វើឱ្យការខូចខាតដល់អ្នកដទៃ។

**ឧទាហរណ៍៖** កញ្ញា **ខ** (អាយុ ១៩ឆ្នាំ) បានធ្វើបាត់ម៉ូតូដែលបានខ្ចីពីមិត្តភក្តិរបស់គាត់។ ដូចនេះហើយ កញ្ញា **ខ** ត្រូវទទួលខុសត្រូវដោយសងសំណងការខូចខាតទៅឱ្យមិត្តរបស់គាត់។

## ១.៤. មូលហេតុនៃការរួចផុតពីការទទួលខុសត្រូវ

ជាគោលការណ៍នៅពេលដែលមានបុគ្គលណាម្នាក់បានប្រព្រឹត្តអំពើបំពានសិទ្ធិ ឬផលប្រយោជន៍របស់អ្នកដទៃ បុគ្គលនោះត្រូវទទួលខុសត្រូវនូវអំពើរបស់ខ្លួនដែលបានប្រព្រឹត្ត។ នៅពេលដែលមានមូលដ្ឋានសំអាងពិសេសដោយផ្អែកលើចរិត និងផលប្រយោជន៍ដែលត្រូវទទួលរងនូវអំពើបំពានរួមទាំងផលប្រយោជន៍ដែលត្រូវ

[19] សន្ធានុក្រមផ្នែករដ្ឋប្បវេណី,ទំព័រ ១០។

បានការពារ នោះបុគ្គលដែលបានធ្វើសកម្មភាពអាចរួចផុតពីការទទួលខុសត្រូវ ទោះបីជាពិនិត្យនៅលើរូបភាពនៃអំពើនោះជាការបំពានដោយខុសច្បាប់លើសិទ្ធិ និងផលប្រយោជន៍របស់ជនដទៃក៏ដោយ ។

### ១.៤.១. ការការពារខ្លួនធម្មានុរូប

ការការពារធម្មានុរូប សំដៅលើអំពើរំលោភដែលពុំអាចជៀសវាងបានដើម្បីការពាររូបរាងកាយ ឬទ្រព្យសម្បត្តិ ឬអ្នកដទៃចំពោះអំពើបំពានមិនត្រឹមត្រូវ ហើយដែលស្ថិតនៅក្នុងករណីដែលអំពើបំពាន និងអំពើរំលោភស្ថិតនៅជិតគ្នាមានតុល្យភាពរវាងវិធីការពារ និងកម្រិតនៃអំពើបំពាននោះ។[20] អំពើការពារធម្មានុរូប មិនមែនជាអំពើបំពានដែលខុសច្បាប់ឡើយ ដោយបុគ្គលដែលបានប្រព្រឹត្តអំពើរំលោភបំពានពុំអាចជៀសវាងបានដើម្បីការពារផលប្រយោជន៍របស់ខ្លួន ឬអ្នកដទៃ។ អាចចាត់ទុកជាការការពារធម្មានុរូបត្រូវស្របតាមលក្ខខណ្ឌដូចខាងក្រោម៖

- មានអំពើបំពានមិនត្រឹមត្រូវ (របស់អ្នកប្រព្រឹត្ត)
- អំពើរំលោភបំពានកើតមានឡើងដែលពុំអាចជៀសបានដើម្បីការពាររូបរាងកាយ ឬទ្រព្យសម្បត្តិរបស់ខ្លួន ឬអ្នកដទៃ
- ពេលវេលានៃអំពើបំពាន និងអំពើរំលោភស្ថិតជិតគ្នា
- តុល្យភាពរវាងវិធីការពារ និងកម្រិតគ្រោះថ្នាក់នោះ។

**ឧទាហរណ៍៖** លោក **ក** និង អ្នកស្រី **ខ** ត្រូវជាប្តីប្រពន្ធនឹងគ្នាបានទាស់ទែងពាក្យសម្តីគ្នារហូតឈានដល់ការប្រើអំពើហិង្សា។ លោក **ក** យកកាំបិតបម្រុងចាក់អ្នកស្រី **ខ** ឱ្យស្លាប់ដោយឃើញសកម្មភាពបែបនេះអ្នកស្រី **ខ** បានយកដំបងដែលនៅក្បែរគាត់ វាយប្រហារតបចំពោះអំពើបំពានរបស់លោក **ក** ដើម្បីការពារខ្លួន។ ក្នុងករណីនេះ អ្នកស្រី **ខ** មិនត្រូវបានទទួលខុសត្រូវអំពើអនីត្យានុកូលនោះទេ ដោយមូលហេតុថាសកម្មភាពបំពាននេះ គឺដើម្បីការពារខ្លួនពីអំពើបំពានពីសំណាក់លោក **ក** តែប៉ុណ្ណោះ។

### ១.៤.២. ស្ថានភាពចាំបាច់

អំពើដោយសារស្ថានភាពចាំបាច់ គឺសំដៅលើអំពើដែលពុំអាចជៀសវាងបានដើម្បីការពាររូបរាងកាយ ឬទ្រព្យសម្បត្តិរបស់ខ្លួន ឬអ្នកដទៃចំពោះគ្រោះថ្នាក់បច្ចុប្បន្ន ឬអាសន្ន ហើយដែលស្ថិតក្នុងករណីមានតុល្យភាព

[20] ក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧, មាត្រា ៧៥៥។

រវាងវិធីការពារ និងកម្រិតគ្រោះថ្នាក់នេះ ។[21] ស្ថានភាពចាំបាច់ ជាលក្ខខណ្ឌមួយដែលនាំឱ្យមិនទទួលខុសត្រូវអំពើអនីត្យានុកូល។ ដើម្បីរួចផុតពីការទទួលខុសត្រូវស្ថានភាពចាំបាច់ត្រូវមានលក្ខខណ្ឌដូចខាងក្រោម៖

- អំពើរំលោភដែលពុំអាចជៀសបាន ដើម្បីការពាររូបរាងកាយ ឬទ្រព្យសម្បត្តិរបស់ខ្លួន ឬអ្នកដទៃ
- ចំពោះគ្រោះថ្នាក់បច្ចុប្បន្ន ឬអច្ចាសន្ន
- ស្ថិតក្នុងករណីមានតុល្យភាពរវាងវិធីការពារ និងកម្រិតគ្រោះថ្នាក់។

ការខូចខាតដែលកើតមានឡើងដោយស្ថានភាពចាំបាច់អ្នកដែលបានប្រព្រឹត្តអំពើការពារ ពុំត្រូវទទួលខុសត្រូវចំពោះអំពើដែលបានប្រព្រឹត្តនោះឡើយ ក្នុងករណីនេះបុគ្គលដែលបានប្រព្រឹត្តអំពើផ្ទុយច្បាប់ដែលជាមូលហេតុនៃអំពើនោះជាអ្នកទទួលខុសត្រូវ។

**ឧទាហរណ៍៖** ដើម្បីកុំឱ្យរថយន្តដឹកទំនិញបើកបុកក្មេងដែលកំពុងឆ្លងថ្នល់ កញ្ញា **ក** បានរត់ទៅទាញក្មេងនោះបណ្តាលឱ្យដួលធ្វើឱ្យក្មេងរបួសដៃបន្តិច ដូចនេះ កញ្ញា **ខ** មិនទទួលខុសត្រូវចំពោះអំពើនេះទេ។

### ១.៤.៣. ការយល់ព្រម ឬការទទួលយកគ្រោះថ្នាក់ពីជនរងគ្រោះ

ជាគោលការណ៍ ការយល់ព្រម និងការទទួលយកនូវគ្រោះថ្នាក់របស់ជនរងគ្រោះធ្វើឱ្យការបំពានសិទ្ធិ ឬផលប្រយោជន៍មានលក្ខណៈស្របច្បាប់ដោយហេតុថា មនុស្សមានសិទ្ធិចាត់ចែងនូវផលប្រយោជន៍របស់ខ្លួនដោយសេរី រាប់បញ្ចូលទាំងការធ្វើឱ្យអន្តរាយផងដែរ ។ ក៏ប៉ុន្តែការយល់ព្រម និងទទួលយកខាងលើនេះទាល់តែជនរងគ្រោះ អាចចាត់ចែងនូវសិទ្ធិ ឬផលប្រយោជន៍របស់ខ្លួនដោយមានសមត្ថភាពក្នុងការបង្ហាញឆន្ទៈ ។ ការយល់ព្រមចាត់ចែងនូវសិទ្ធិ ឬផលប្រយោជន៍របស់ជនរងគ្រោះមិនត្រូវផ្ទុយនឹងសណ្តាប់ធ្នាប់សាធារណៈ និងទំនៀមទំលាប់ល្អរបស់សង្គម ។[22]

**ឧទាហរណ៍៖** ការវះកាត់ដើម្បីព្យាបាលអ្នកជំងឺ។

ប៉ុន្តែករណីដែលការយល់ព្រមមិនត្រូវបានសង្គមទទួលស្គាល់ថា សមហេតុផល មិនអាចរួចផុតពីភាពផ្ទុយច្បាប់ឡើយ ។ [23]

---

[21] ក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧, មាត្រា ៧៥៥។

[22] សេចក្តីពន្យល់ក្រមរដ្ឋប្បវេណី, (ភ្នំពេញ៖សាលាភូមិន្ទរដ្ឋបាល,២០១២) ភាគ ៤,ទំព័រ ២៦។

[23] ក្រមរដ្ឋប្បវេណី ឆ្នាំ ២០០៧, មាត្រា ៧៥៦ វាក្យខណ្ឌទី១។

# ជំពូកទី២
# ការទទួលខុសត្រូវចំពោះ
# អំពើរបស់អ្នកដទៃ

# ជំពូកទី២

# ការទទួលខុសត្រូវចំពោះអំពើរបស់អ្នកដទៃ

អំពើអនីត្យានុកូល គឺជាអំពើផ្ទុយនឹងច្បាប់ដែលប្រព្រឹត្តដោយបុគ្គលម្នាក់ ឬមួយក្រុម ហើយធ្វើប៉ះពាល់ដល់សិទ្ធិសេរីភាព សេចក្តីថ្លៃថ្នូរ បូរណភាពរូបរាងកាយ ឬខូចខាតប្រយោជន៍អ្នកដទៃ។ អំពើអនីត្យានុកូលបែងចែកចេញបី គឺ ការទទួលខុសត្រូវចំពោះទង្វើរបស់ខ្លួនឯង ការទទួលខុសត្រូវចំពោះអំពើសត្វ និងវត្ថុ ការទទួលខុសត្រូវអំពើរបស់អ្នកដទៃ។ ចំពោះការទទួលខុសត្រូវអំពើរបស់អ្នកដទៃ គឺជាការទទួលខុសត្រូវចំពោះការខូចខាតដែលបង្កឡើងដោយអ្នកដទៃដោយអ្នកប្រព្រឹត្តមានទំនាក់ទងគតិយុត្ត ហើយបុគ្គលម្នាក់ទៀតនៅជាអ្នកទទួលខុសត្រូវ។

ការទទួលខុសត្រូវចំពោះអំពើរបស់អ្នកដទៃមានដូចជា ការទទួលខុសត្រូវរបស់អ្នកមានករណីយកិច្ចត្រួតពិនិត្យ ការទទួលខុសត្រូវរបស់និយោជក ការទទួលខុសត្រូវរបស់នីតិបុគ្គល និងការទទួលខុសត្រូវលើអំពើអនីត្យានុកូលរបស់មន្ត្រីរាជការ។

## ២.១. ការទទួលខុសត្រូវរបស់អ្នកមានករណីយកិច្ចត្រួតពិនិត្យ

អសមត្ថជន ជាជនដែលស្ថិតក្នុងស្ថានភាពដែលមិនអាចយល់ដឹង នឹងវិនិច្ឆ័យបានអំពីការទទួលខុសត្រូវរបស់ខ្លួន នៅពេលដែលខ្លួនបានប្រព្រឹត្តអំពើបំពានដែលប៉ះពាល់ដល់អ្នកដទៃ។ បុគ្គលទាំងនេះមិនតម្រូវឱ្យទទួលខុសត្រូវអំពើអនីត្យានុកូលរបស់ខ្លួនទេ ចំពោះសំណងខូចខាតគឺបុគ្គលដែលមានករណីយកិច្ចក្នុងការត្រួតពិនិត្យត្រូវសងការខូចខាតរបស់អ្នកដទៃ ដែលកើតឡើងដោយអំពើបំពានរបស់បុគ្គលនៅក្រោមការត្រួតពិនិត្យរបស់ខ្លួន។

### ២.១.១. អនីតិជនអាយុក្រោម ១៤ឆ្នាំ

អនីតិជនដែលមានអាយុក្រោម១៤ឆ្នាំ មិនត្រូវទទួលខុសចំពោះអំពើអនីត្យានុកូលទេ។ នៅពេលជនទាំងនោះបានប្រព្រឹត្តអំពើបំពានសិទ្ធិ ឬប្រយោជន៍អ្នកដទៃ ជននោះមិនត្រូវឱ្យទទួលខុសត្រូវការខូចខាតដែលគាត់បានបង្កឡើងឡើយ។

ការសងសំណងការខូចខាត គឺជាបុគ្គលដែលមានករណីយកិច្ច ដែលបានកំណត់ដោយច្បាប់ក្នុងការត្រួតពិនិត្យអនីតិជនក្រោមអាយុ ១៤ឆ្នាំមានករណីយកិច្ចត្រូវសងការខូចខាតរបស់អ្នកដទៃដែលកើតឡើង

ដោយសារអំពើបំពានរបស់បុគ្គលនៅក្រោមការត្រួតពិនិត្យខ្លួននេះ។ [24] ទោះបីជាអនីតិជនបានប្រព្រឹត្តអំពើបំពានដោយចេតនាក្តី ឬអចេតនាក្តី ការទទួលខុសត្រូវចំពោះព្យសនកម្មដែលបានបង្កដោយអំពើនោះជាកាតព្វកិច្ចរបស់បុគ្គលមានករណីយកិច្ចត្រួតពិនិត្យ។ បុគ្គលដែលមានករណីយកិច្ចក្នុងការត្រួតពិនិត្យអាចជាឪពុកម្តាយ ឬអាណាព្យាបាលរបស់អនីតិជនក្រោម ១៤ឆ្នាំនោះ។

ដូច្នេះហើយ ទោះបីជាឪពុកម្តាយ ឬអាណាព្យាបាលមិនមានកំហុសចំពោះអំពើបំពានក៏ដោយ តែត្រូវទទួលខុសត្រូវនូវទង្វើនេះ ដែលកើតមកពីបុគ្គលដែលស្ថិតក្រោមការត្រួតពិនិត្យរបស់ខ្លួន។ ដើម្បីឱ្យអ្នកមានករណីយកកិច្ចត្រួតពិនិត្យទទួលខុសត្រូវអំពើអនីត្យានុកូល លុះត្រាតែ៖

- អនីតិជនក្រោមអាយុ ១៤ឆ្នាំ បានប្រព្រឹត្តកំហុសអចេតនា ឬចេតនា
- ព្យសនកម្មដែលកើតមានឡើងជាអំពើរបស់អនីតិជន
- អនីតិជនត្រូវអាយុក្រោមអាយុ១៤ឆ្នាំ ដាច់ខាត
- អនីតិជន ត្រូវនៅក្រោមការគ្រប់គ្រងរបស់អ្នកមានករណីយកិច្ចត្រួតពិនិត្យ។

**ឧទាហរណ៍**៖ លោក **ក** និង អ្នកស្រី **ខ** មានកូនស្រីម្នាក់អាយុ ៧ឆ្នាំ។ ថ្ងៃមួយកូនស្រីរបស់គាត់បានលេងបរិវេណផ្ទះរបស់គាត់ ហើយយកដុំថ្មគប់ទៅលើដើមស្វាយក្បែរផ្ទះ តែបែរជាត្រូវកញ្ចក់បង្អួចផ្ទះរបស់អ្នកជិតខាងបណ្តាលឱ្យបង្អួចនោះបែក។

ក្នុងករណីនេះយើងសង្កេតឃើញថា មានការខូចខាតកើតឡើង (បែកកញ្ចក់បង្អួច) ដែលបង្កឡើងដោយអំពើរបស់កូនស្រីលោក **ក** និង អ្នកស្រី **ខ** មានអាយុ ៧ឆ្នាំ។ ដូចនេះហើយកូនស្រី លោក **ក** និង អ្នកស្រី **ខ** មិនទទួលខុសត្រូវអំពើអនីត្យានុកូលនោះទេ ដោយតែនាងជាអនីតិជនក្រោមអាយុ ១៤ឆ្នាំ។ ដូចនេះហើយ ការទទួលខុសត្រូវលើព្យសនកម្មនេះ ករណីយកិច្ចរបស់លោក **ក** និងអ្នកស្រី **ខ** ដែលត្រូវជួសជុលសំណងការខូចខាតដល់អ្នកជិតខាងរបស់គាត់។

### ២.១.២. អនីតិជនចាប់ពីអាយុ ១៤ឆ្នាំ ដល់ក្រោម ១៨ឆ្នាំ

យោងតាមមាត្រា ៧៤៦ នៃក្រមរដ្ឋប្បវេណីបានចែងថា បុគ្គលដែលមានករណីយកិច្ចដែលបានកំណត់ដោយច្បាប់ក្នុងការត្រួតពិនិត្យអនីតិជនអាយុចាប់ពី ១៤ (ដប់បួន)ឆ្នាំ ឡើងទៅត្រូវទទួលខុសត្រូវដោយសាមគ្គីភាពជាមួយអនីតិជន ចំពោះការខូចខាតរបស់អ្នកដទៃដែលកើតឡើងដោយអំពើអនីត្យានុកូលរបស់អនីតិជននោះ មានន័យថានៅពេលដែលមានអំពើអនីត្យានុកូលកើតឡើងដែលបង្កដោយអនីតិជនដែលមាន

[24] ក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧, មាត្រា ៧៤៦។

អាយុចាប់ពី១៤ឆ្នាំ ដល់ក្រោម១៨ឆ្នាំ អនីតិជនត្រូវទទួលខុសត្រូវដោយសាមគ្គីភាពជាមួយអ្នកដែលមានករណីយកិច្ចត្រួតពិនិត្យអាចជា ឪពុកម្តាយ ឬអាណាព្យាបាលសម្រាប់អនីតិជននោះ។

ដើម្បីឱ្យមានការទទួលខុសត្រូវរបស់អ្នកមានករណីយកិច្ចត្រួតពិនិត្យ ជនរងគ្រោះត្រូវបង្ហាញអំពីភស្តុតាង៖

- **ការខូចខាត៖** ព្យសនកម្មត្រូវបានបង្កឡើងអំពើរបស់អនីតិជន។
- **ទំនាក់ទំនងហេតុ និងផល៖** ទំនាក់ទំនងហេតុផលរវាងអំពើរបស់អនីតិជន និងការខូចខាតកើតមានឡើងដោយសារអំពើរបស់អនីតិជន។
- **កំហុសរបស់អនីតិជន៖** អនីតិជនបានប្រព្រឹត្តអំពើដោយកំហុសចេតនា ឬអចេតនា។
- អនីតិជនត្រូវមានអាយុស្ថិតក្រោម១៨ឆ្នាំដាច់ខាត
- អនីតិជនត្រូវស្ថិតការអប់រំថែរក្សាដោយអ្នកដែលមានករណីកិច្ចត្រួតពិនិត្យ (ឪពុកម្តាយ ឬអាណាព្យាបាល)។[25]

**ឧទាហរណ៍៖** លោក **គ** និង លោកស្រី **ឃ** មានកូនប្រុសម្នាក់ឈ្មោះ **ង** អាយុ១៧ ឆ្នាំ។ ដោយសារជីវភាពខ្វះខាត កូនប្រុសរបស់គាត់ត្រូវផ្អាកពីការសិក្សា ហើយបានទៅធ្វើការជាបុគ្គលិកនៅហាងកាហ្វេមួយកន្លែង។ នៅពេលធ្វើដំណើរត្រឡប់មកពីធ្វើការវិញ **ង** បានជួបជុំជាមួយមិត្តភក្តិរបស់គេ ហើយក៏បានទាស់សម្តីគ្នាជាមួយមិត្តភក្តិ រហូតឈានទៅដល់វាយតប់គ្នាកើតឡើង។ **ង** បានវាយមិត្តភក្តិរបស់ខ្លួនឱ្យរងរបួសបាក់ដៃម្ខាង។

ក្នុងករណីនេះ លោក **គ** អ្នកស្រី **ឃ** និង **ង** ត្រូវទទួលខុសត្រូវរួមគ្នាដើម្បីសងការខូចខាតទៅឱ្យជនរងគ្រោះ។ ទោះបីជា លោក **គ** និង អ្នកស្រី **ឃ** គ្មានកំហុសក្នុងអំពើនៃក្តី តែត្រូវទទួលខុសត្រូវផងដែរ ដោយសារបុគ្គលដែលបានប្រព្រឹត្តកំហុសជាកូនរបស់គាត់ ហើយ **ង** បានរស់នៅជាមួយគាត់ និងស្ថិតក្រោមការគ្រប់គ្រងរបស់គាត់។

បើសិនជាអនីតិជននោះគ្មានលទ្ធភាពក្នុងការសងសំណងខូចខាតដែលខ្លួនបានប្រព្រឹត្តដោយហេតុថា អនីតិជននោះអាចស្ថិតក្នុងវ័យសិក្សាមិនទាន់អាចរកប្រាក់ចំណូលខ្លួនឯងបាន នោះឪពុកម្តាយ ឬអាណាព្យាបាល អ្នកដែលមានករណីយកិច្ចត្រួតពិនិត្យដែលច្បាប់បានកំណត់ត្រូវទទួលខុសត្រូវនូវអំពើអំពើអនីត្យានុកូលដែលបង្កឡើងដោយអនីតិជននោះទាំងស្រុង។

[25] សាស្ត្រាចារ្យ ញឹក វុធ្ធី, នីតិកាតព្វកិច្ចក្រៅកិច្ចសន្យា,ទំព័រ ៣២។

ដើម្បីឱ្យរួចផុតពីការទទួលខុសត្រូវ ឪពុកម្តាយអាចបង្ហាញភស្តុតាងថា៖

- គាត់មិនបានប្រព្រឹត្តកំហុសខាងការថែទាំ ឃ្លាំមើល ឬខាងអប់រំទេ
- ឬមួយគាត់មិនបានរស់នៅជាមួយកូនគាត់ទេ ហេតុនេះគាត់មិនមានលទ្ធភាពឃ្លាំមើលដល់ការអប់រំ ឬដល់ការថែទាំកូនគាត់ពេលមានហេតុបង្កការខូចខាតដល់អ្នកដទៃ។[26]

**ឧទាហរណ៍**៖ លោក **ក** មានកូនប្រុសម្នាក់ឈ្មោះ **ច** អាយុ ១៥ ឆ្នាំ ដោយកូនរបស់កូននៅសិក្សា មិនទាន់អាចរកប្រាក់ចំណូលឱ្យខ្លួនឯងបាននោះទេ។ ថ្ងៃមួយ **ច** បានខ្ចីកង់របស់មិត្តភក្តិយកមកជិះលេងធ្វើឱ្យបាត់។ ដូចនេះហើយ នៅក្នុងករណីនេះ ដោយសារតែ **ច** កំពុងនៅសិក្សា ហើយមិនទាន់រកប្រាក់ចំណូល មិនអាចមានលទ្ធភាពសងការខូចខាតទៅឱ្យមិត្តរបស់ខ្លួនទេ។ ដូចនេះ លោក **ក** ដែលជាឪពុករបស់ **ច** មានត្រូវទទួលខុសត្រូវសងការខូចខាចទៅឱ្យជនរងគ្រោះ។

### ២.១.៣. ជនមានវិបត្តិផ្នែកស្មារតី

ជនមានវិបត្តិផ្នែកបញ្ញាស្មារតី គឺជាជនដែលមិនអាចយល់ដឹង និងវិនិច្ឆ័យបានអំពីការទទួលខុសត្រូវចំពោះអំពើរបស់ខ្លួន។ បុគ្គលដែលមានវិបត្តិផ្នែកបញ្ញាស្មារតីមិនត្រូវបានទទួលខុសត្រូវអំពើអនីត្យានុកូលឡើយដោយហេតុថា បុគ្គលមិនអាចពិចារណាអំពីអំពើរបស់ខ្លួនត្រឹមត្រូវ ឬមិនត្រឹមត្រូវ។ ហើយបុគ្គលដែលបានកំណត់ដោយច្បាប់ ក្នុងការត្រួតពិនិត្យបុគ្គលដែលមានវិបត្តិផ្នែកបញ្ញាស្មារតីមានករណីយកិច្ចត្រូវសងការខូចខាតនោះ។

ជនរងគ្រោះអាចទាមទារសំណងពីអ្នកមានករណីយកិច្ចត្រួតពិនិត្យបាន ក្នុងលក្ខខណ្ឌដូចខាងក្រោម៖

- ព្យសនកម្មកើតមានឡើងដោយជនមានវិបត្តិផ្នែកស្មារតី
- ជនមានវិបត្តិផ្នែកស្មារតីបានប្រព្រឹត្តកំហុសចេតនា ឬអចេតនា
- ទំនាក់ទំនងហេតុផលរវាងអំពើរបស់ជនមានវិបត្តិផ្នែកស្មារតី និងព្យសនកម្មកើតមានឡើងដោយសារអំពើរបស់ជននោះ។
- ជនដែលមានវិបត្តិផ្នែកស្មារតីត្រូវស្ថិតក្រោមការគ្រប់គ្រង និងមើលថែរក្សាដោយបុគ្គលដែលមានករណីយកិច្ចត្រួតពិនិត្យ។

**ឧទាហរណ៍**៖ លោក **ក** និងអ្នកស្រី **ខ** មានកូនម្នាក់ដែលមានវិបត្តិផ្នែកស្មារតីតាំងពីកំណើត។ ថ្ងៃមួយកូនរបស់គាត់បានទៅវាយអ្នកដំណើរដើរថ្មើរជើងនៅតាមផ្លូវបណ្តាលឱ្យរបួសក្បាល ។

[26] សាស្ត្រាចារ្យ ញឹក វុធ្ធី, នីតិកាតព្វកិច្ចក្រៅកិច្ចសន្យា,ទំព័រ ៣៣។

ក្នុងករណីនេះ យើងសង្កេតឃើញថា មានព្យសនកម្ម(បែកក្បាល) កើតឡើងដែលបង្កឡើងដោយកូនរបស់លោក **ក** និងអ្នកស្រី **ខ** ដែលមានវិបត្តិផ្នែកស្មារតី។ កូនរបស់គាត់មិនត្រូវបានទទួលខុសត្រូវអំពើរបស់ខ្លួនទេ ដោយហេតុថាកូនរបស់គាត់មិនអាចយល់ដឹងអំពើរបស់ខ្លួនប្រព្រឹត្តត្រឹមត្រូវ ឬមិនត្រឹមត្រូវ។ ដូចនេះហើយលោក **ក** និងអ្នកស្រី **ខ** ត្រូវទទួលខុសត្រូវអំពើរបស់កូនគាត់ ដែលស្ថិតនៅក្រោមការគ្រប់គ្រងមើលថែរក្សារបស់ពួកគាត់។

## ២.២. ការទទួលខុសត្រូវរបស់និយោជក

**និយោជក** សំដៅដល់រូបវន្តបុគ្គល ឬនីតិបុគ្គលសាធារណៈ ឬឯកជនដែលដឹកនាំ គ្រប់គ្រង និងប្រើកម្មករនិយោជិតម្នាក់ ឬច្រើននាក់ ទោះជាមិនជាប់លាប់ក្តី ដោយមានផ្តល់ប្រាក់កម្រៃជាទៀងទាត់។[27] រីឯនិយោជិត គឺជនដែលបានចុះកិច្ចសន្យាជួយធ្វើការបុគ្គលណាម្នាក់ដោយយកកម្រៃ។[28] នៅពេលដែលនិយោជកប្រើឱ្យនិយោជិតអនុវត្តកាតព្វកិច្ចមួយ ហើយនិយោជិតបានប្រព្រឹត្តអំពើបំពាន ឬមានគ្រោះថ្នាក់ការងារកើតឡើង និយោជកត្រូវទទួលខុសត្រូវនៅអំពើនោះ។

យោងទៅតាមច្បាប់ស្តីពីការងារនៅក្នុងមាត្រា ២៤៨ បានចែងយ៉ាងច្បាស់អំពីអត្ថន័យគ្រោះថ្នាក់ការងារថា៖

- ត្រូវចាត់ទុកជាគ្រោះថ្នាក់ការងារ គ្រោះថ្នាក់ដែលកើតឡើងដោយធ្វើការ ឬក្នុងពេលធ្វើការទោះដោយហេតុយ៉ាងណាក៏ដោយ ហើយទោះមានកំហុសមកពីកម្មករនិយោជិត ឬគ្មានក៏ដោយគឺគ្រោះថ្នាក់ដែលធ្លាក់លើរូបកាយកម្មករនិយោជិត ក្នុងពេលធ្វើការឱ្យនិយោជក ឬនាយកសហគ្រាស ឬថ្នាក់លើសិស្សវិជ្ជាជីវៈមានឈ្នួលក្តី ឥតឈ្នួលក្តី កាន់មុខងារជាអ្វីនៅទីកន្លែងណាក៏ដោយ ។
- ម្យ៉ាងទៀតត្រូវចាត់ទុកជាគ្រោះថ្នាក់ការងារដែរ ចំពោះគ្រោះថ្នាក់ណាដែលធ្លាក់លើកម្មករនិយោជិតក្នុងពេលដែលសាមីខ្លួនធ្វើដំណើរពីលំនៅដ្ឋានខ្លួនត្រង់ឆ្ពោះទៅទីកន្លែងធ្វើការ ឬវិលមកវិញដោយគ្មានឈប់ ឬដោយគ្មានវាងទៅកន្លែងផ្សេងជាប្រយោជន៍ផ្ទាល់ខ្លួន ឬក្រៅពីការងារដែលគេតម្រូវឱ្យទៅ។ ជំងឺបណ្តាលមកពីវិជ្ជាជីវៈទាំងអស់ដូចមានបញ្ជាក់ក្នុងច្បាប់ត្រូវចាត់ទុកជាគ្រោះថ្នាក់ការងារហើយទទួលការជួសជុលដូចគ្នាដែរ ។

សរុបមកគ្រោះថ្នាក់ការងារ សំដៅដល់គ្រោះថ្នាក់ដែលកើតឡើងដោយចៃដន្យ និងភ្លាមៗក្នុងពេលធ្វើការងារដោយធ្វើការងារ ឬនៅកន្លែងធ្វើការងារដោយមូលហេតុទាក់ទងនឹងកំហុសជនរងគ្រោះ ឬគ្មាន

[27] វចនានុក្រមតម្រាច្បាប់

[28] ច្បាប់ស្តីពីការងារឆ្នាំ ១៩៩៧, មាត្រា៣។

កំហុសក៏ដោយដែលបណ្តាលឱ្យជនរងគ្រោះទទួលរងរបួសស្នាមជាយថាហេតុ។ គ្រោះថ្នាក់ពេលធ្វើដំណើរ សំដៅដល់គ្រោះថ្នាក់កើតឡើងពេលធ្វើដំណើរនៅលើកំណាត់ផ្លូវត្រង់រវាងលំនៅឋាន និងកន្លែងធ្វើការងារ ក្នុងចិរវេលាសមស្រប។

ដូច្នេះហើយនៅពេលមានគ្រោះថ្នាក់ការងារកើតឡើងលើនិយោជិតក្នុងកំឡុងពេលបំពេញការងារ ឱ្យនិយោជក នោះនិយោជកត្រូវទទួលខុសត្រូវនូវការខូចខាតដែលកើតឡើងដោយអំពើរបស់និយោជិត។

### ២.២.១. លក្ខខណ្ឌក្នុងការទទួលខុសត្រូវ

និយោជក ត្រូវទទួលខុសត្រូវនូវអំពើបំពានសិទ្ធិ ឬផលប្រយោជន៍របស់អ្នកដទៃគ្រោះថ្នាក់ការងារនៅកំឡុងពេលដែលនិយោជិតអនុវត្តកិច្ចការតាមបញ្ជារបស់និយោជក។ និយោជកត្រូវទទួលខុសត្រូវលើគ្រោះថ្នាក់ការងារទាំងអស់ ដោយការទទួលខុសត្រូវនៅត្រូវអនុវត្តលើ៖

- អ្នកគ្រប់គ្រងគ្រឹះស្ថានព្យាបាលឯកជន ចំពោះតែបុគ្គលិកដែលអ្នកគ្រប់គ្រងនេះប្រើ
- ជនដែលមានវិជ្ជាជីវៈសេរី ចំពោះតែគ្រោះថ្នាក់លើកម្មករនិយោជិតរបស់ជននោះ
- សហគ្រាសសិប្បកម្ម ចំពោះកម្មករនិយោជិតក្រៅពីប្រពន្ធ កូនរបស់សិប្បករ
- ម្ចាស់ផ្ទះ ចំពោះតែគ្រោះថ្នាក់លើអ្នកបម្រើក្នុងផ្ទះរបស់ខ្លួន
- សហគ្រាសកសិកម្ម ចំពោះគ្រោះថ្នាក់នៃកម្មករនិយោជិតក្នុងសហគ្រាសនោះ ។[29]

ក្រៅពីប្រភេទដូចមានចែងជាក់លាក់ក្នុងកថាខណ្ឌខាងដើមនេះជនណាដែលទទួលកម្មករនិយោជិតឱ្យប្រកបការណាមួយជាប្រាកដ និងម្តងម្កាលឱ្យខ្លួនត្រូវតែជួសជុលគ្រោះថ្នាក់ផ្សេងៗ ដែលកម្មករនិយោជិតត្រូវរងគ្រោះក្នុងឱកាសដែលបំពេញការងារនោះ ។

ដើម្បីឱ្យនិយោជកទទួលខុសត្រូវសងសំណងនៃការខូចខាតដែលកើតឡើងដោយសារអំពើ អនីត្យានុកូលរបស់និយោជិត ត្រូវបំពេញនូវលក្ខខណ្ឌដូចខាងក្រោម៖

- ការប្រើនិយោជិតដើម្បីអនុវត្តកិច្ចការណាមួយជាកំណត់ហើយអំពើអនីត្យានុកូលនោះកើតឡើងនៅក្នុងអំឡុងពេលដែលនិយោជិតអនុវត្តកិច្ចការរបស់ខ្លួន
- ព្យសនកម្មដែលកើតមានឡើងគឺជាអំពើរបស់និយោជិត
- និយោជិតប្រព្រឹត្តកំហុសដោយចេតនា ឬដោយអចេតនា។

[29] ច្បាប់ស្តីពីការងារឆ្នាំ ១៩៩៧, មាត្រា២៩៩។

**ឧទាហរណ៍៖** លោក **ក** បានធ្វើការជាអ្នកដឹកជញ្ជូនម្ហូបនៅហាងលក់ម្ហូបកម្មង់មួយកន្លែង។ កំឡុងពេលគាត់បានធ្វើដំណើរដឹកជញ្ជូនម្ហូបដែលអតិថិជនបានកម្មង់ ពីកន្លែងហាងលក់ម្ហូបទៅផ្ទះរបស់អតិថិជន។ នៅពេលធ្វើដំណើរតាមផ្លូវគាត់បានជួបឧបទ្ទវហេតុគ្រោះថ្នាក់ចរាចរណ៍ដោយសារធ្វេសប្រហែសក្នុងការបើកបរ បណ្តាលឱ្យបុកជាមួយម៉ូតូអ្នករួមដំណើរតាមដងផ្លូវ ធ្វើឱ្យម៉ូតូជនរងគ្រោះមានការខូចខាតជាខ្លាំង។

ក្នុងករណីបានបង្ហាញឱ្យឃើញពីលក្ខខណ្ឌដែលនាំឱ្យនិយោជកដែលម្ចាស់ហាងម្ហូបកម្មង់ដូចខាងក្រោម៖

- ម្ចាស់ហាងបានប្រើឱ្យលោក **ក** ដឹកជញ្ជូនម្ហូបឱ្យអតិថិជនហើយអំពើអនីត្យានុកូលកើតមានឡើងពេលលោក **ក** បានបំពេញការងាររបស់ខ្លួន
- ព្យសនកម្ម(ខូចខាតម៉ូតូ) គឺជាអំពើរបស់លោក **ក**
- លោក **ក** បានប្រព្រឹត្តកំហុសដោយអចេតនា។

### ២.២.២. ការទទួលខុសត្រូវ

យោងតាមមាត្រា៧៤៧ នៃក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧ ចែងអំពីការទទួលខុសត្រូវរបស់និយោជកដូចខាងក្រោម៖

១. បុគ្គលដែលប្រើនិយោជិតដើម្បីអនុវត្តកិច្ចការ ត្រូវទទួលខុសត្រូវការសងការខូចខាតដែលនិយោជិតបានបង្កដល់អ្នកដទៃដោយខុសច្បាប់ដោយកំហុសចេតនា ឬដោយកំហុសអចេតនា នៅក្នុងការអនុវត្តកិច្ចការនោះ។

២. បុគ្គលដែលស្ថិតក្នុងឋានៈត្រូវត្រួតពិនិត្យនិយោជិតជំនួសនិយោជក ត្រូវទទួលខុសត្រូវដូចគ្នានឹងនិយោជកដែរ។ ប៉ុន្តែបញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយចំពោះ ករណីដែលបុគ្គលនោះបានត្រួតពិនិត្យដោយត្រឹមត្រូវ។

៣. និយោជក ឬអ្នកត្រួតពិនិត្យជំនួសអាចទាមទារសំណងពីនិយោជិតបានដោយយោងទៅតាមកម្រិតនៃកំហុសរបស់និយោជិតនោះ។

មានន័យថា **និយោជក** ត្រូវទទួលខុសត្រូវក្នុងការសងការខូចខាត ប៉ុន្តែនិយោជកអាចទាមទារសំណងពីនិយោជិតបានដោយយោងទៅតាមកម្រិតនៃកំហុសរបស់និយោជិតនោះ។ អ្នកត្រួតពិនិត្យជំនួសត្រូវទទួលខុសត្រូវដូចគ្នានឹងនិយោជកដែរ។ ប៉ុន្តែអ្នកត្រួតពិនិត្យអាចរួចផុតពីការទទួលខុសត្រូវ បើអាចបង្ហាញថាបាន

ត្រួតពិនិត្យដោយត្រឹមត្រូវ។ អ្នកត្រួតពិនិត្យជំនួសអាចទាមទារសំណងពីនិយោជិតបានដោយយោងទៅតាមកម្រិតនៃកំហុសរបស់និយោជិតនោះ។[30]

**ឧទាហរណ៍៖** ម្ចាស់ហាងកាហ្វេឈ្មោះ **ក** បានប្រើឱ្យនិយោជិតទៅយកទំនិញ( កាហ្វេ) ពីខេត្តមណ្ឌលគិរី។ នៅកំឡុងបើរថយន្តធ្វើដំណើរទៅខេត្តមណ្ឌលគិរី និយោជិតនោះបានជួបគ្រោះថ្នាក់ចរាចរប៉ះជាមួយម៉ូតូបុរសម្នាក់ដែលធ្វើដំណើរនៅតាមដងផ្លូវ។

នៅក្នុងអង្គហេតុនេះ និយោជកត្រូវទទួលអំពើអនីត្យានុកូលរបស់និយោជិតព្រោះ៖

- និយោជកប្រើឱ្យនិយោជិតបំពេញការងារដឹកជញ្ជូនទំនិញ
- និយោជិតបានប្រព្រឹត្តកំហុស
- ការខូចខាតកើតឡើងនៅពេលនិយោជិតអនុវត្តកិច្ចការដែលនិយោជកឱ្យបំពេញ។

### ២.២.៣. ការរួចផុតពីការទទួលខុសត្រូវ

ជាគោលការណ៍នៅពេលនិយោជិតបានប្រព្រឹត្តអំពើបំពាន ឬធ្វើឱ្យខូចខាតនូវផលប្រយោជន៍អ្នកដទៃដោយកំហុសចេតនា ឬអចេតនានិយោជិតមិនត្រូវទទួលខុសត្រូវនូវអំពើដែលខ្លួនប្រព្រឹត្តចំពោះអ្នកដទៃនោះទេ ហើយនិយោជកដែលជាអ្នកប្រើឱ្យនិយោជិតបំពេញការងារឱ្យខ្លួន ត្រូវទទួលខុសនូវអំពើអនីត្យានុកូលដែលនិយោជិតបានប្រព្រឹត្ត។

ប៉ុន្តែនិយោជកអាចក៏រួចផុតពីការទទួលខុសត្រូវ លុះត្រាតែក្នុងលក្ខខណ្ឌដូចខាងក្រោម៖

- កំហុសរបស់និយោជិតកើតឡើងមិនស្ថិតក្នុងកំឡុងពេលបំពេញការងារ។
- និយោជិតប្រព្រឹត្តកំហុសក្នុងម៉ោងការងារ តែក្នុងគោលដៅផ្សេងពីផលប្រយោជន៍របស់និយោជក
- កំហុសរបស់និយោជិត ជាកំហុសនៅក្រៅមុខងារទាំងស្រុង។
- និយោជក ឬអ្នកត្រួតពិនិត្យជំនួសបានធ្វើការត្រួតពិនិត្យត្រឹមត្រូវ។

**ឧទាហរណ៍៖** លោក **ក** ជាអ្នកបើករថយន្តឱ្យលោក **ខ** ។ លោក **ខ** បានឱ្យលោក **ក** ជូនទៅភោជនីយដ្ឋានមួយដើម្បីជួបជាមួយអតិថិជនរបស់គាត់។ ពេលទៅដល់ភោជនីយដ្ឋានលោក **ខ** បានឱ្យលោក **ក** ចាំគាត់នៅក្រៅភោជនីយដ្ឋាននៅកំឡុងពេលជួបជាមួយអតិថិជន។ ដោយសារមានការធុញថប់ក្នុងការរង់ចាំលោក **ខ** ត្រឡប់មកវិញ លោក **ក** បានបើករថយន្តចេញពីភោជនីយដ្ឋានដើម្បីលំហែអារម្មណ៍សិន។ តែដោយសារការធ្វេសប្រហែសនិយាយទូស័ព្ទក្នុងពេលបើកបរធ្វើឱ្យបើរថយន្តបុកទៅនឹងអ្នកថ្មើរជើងបណ្ដាលឱ្យបាក់ដៃស្ដាំ។

---

[30] ក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧, មាត្រា ៧៤៧។

ក្នុងករណីនេះ ទោះបីជាការខូចខាតកើតក្នុងកំឡុងពេលបំពេញការងារក៏ដោយតែលោក **ក** បានប្រព្រឹត្ត អំពើផ្ទុយនឹងទិសដៅការងារដែលលោក **ខ** បានឱ្យបំពេញ។ ហើយកំហុសកើតឡើងដោយការធ្វេសប្រហែស និងក្រៅមុខងារទាំងស្រុង។ ដូចនេះ លោក **ខ** ដែលត្រូវជានិយោជករបស់លោក **ក** មិនត្រូវទទួលខុសត្រូវនូវ អំពើរបស់និយោជិតរបស់ខ្លួន ដែលបានធ្វើឱ្យមានខូចខាតដល់អ្នកដទៃនោះទេ។

### ២.២.៤. ការទាមទារសំណងពីនិយោជិត

នៅពេលដែលនិយោជិតបានប្រព្រឹត្តកំហុសប៉ះពាល់ដល់ផលប្រយោជន៍អ្នកដទៃ និយោជកត្រូវ ទទួលខុសត្រូវដោយគ្មានកំហុសរបស់និយោជកទៅលើនិយោជិតរបស់ខ្លួន ប៉ុន្តែនិយោជកក៏អាចទាមទារ សំណងពីនិយោជិតបានដែរ។[31] ដោយសារតែនិយោជិត គឺជាចារីផ្ទាល់និយោជក ឬអ្នកត្រួតពិនិត្យអាច ទាមទារសំណងពីនិយោជិតបាន ក្នុងករណីដែលនិយោជក ឬអ្នកត្រួតពិនិត្យបានសងសំណងទៅភាគី រងគ្រោះ។ ប៉ុន្តែនិយោជក ឬអ្នកត្រួតពិនិត្យមិនអាចទទួលបានមកវិញនូវប្រាក់ទាំងអស់នោះទេ ប៉ុន្តែអាច ទទួលបានដោយយោងទៅតាមកម្រិតនៃកំហុសជាក់ស្តែងរបស់និយោជិត។

ស្តីពីអំពើអនីត្យានុកូលដែលធ្វើឡើងដោយនិយោជិត (មនុស្សដែលនិយោជកបានប្រើដើម្បីប្រកប អាជីវកម្មរបស់ខ្លួន) សាមីខ្លួនដែលជានិយោជិតត្រូវទទួលខុសត្រូវ ហើយថែមពីលើនេះ និយោជក ឬអ្នកដែល ត្រួតពិនិត្យជំនួសនិយោជក (អ្នកតំណាងអ្នកត្រួតពិនិត្យ) ក៏ត្រូវទទួលខុសត្រូវជាមួយនឹងនិយោជិតនោះដែរ ដោយគ្មានពាក់ព័ន្ធនឹងកំហុសចេតនា ឬអចេតនារបស់និយោជិតទេ ។

ការឱ្យនិយោជកទទួលខុសត្រូវនេះ គឺដោយផ្អែកលើគំនិតថា ការបាត់បង់ក៏ស្ថិតនៅកន្លែងដែលផល ប្រយោជន៍ស្ថិតនៅ ។

ក្នុងករណីដែលអ្នកតំណាងអ្នកត្រួតពិនិត្យបានធ្វើការត្រួតពិនិត្យនិយោជិតបានត្រឹមត្រូវ អ្នកតំណាង នោះនឹងរួចផុតពីការទទួលខុសត្រូវនេះ ប៉ុន្តែនិយោជកខ្លួនឯងផ្ទាល់មិនអាចរួចផុតពីការទទួលខុសត្រូវនោះទេ។[32] និយោជកមិនអាចរួចផុតពីការទទួលខុសត្រូវ ដោយការបង្ហាញថាខ្លួនមិនបានប្រព្រឹត្តនូវកំហុសណាមួយ ឬ គ្មានកំហុសក្នុងការគ្រប់គ្រងលើនិយោជិតរបស់ខ្លួនទេ។ និយោជកត្រូវទទួលខុសត្រូវសងការខូចខាតទៅជន រងគ្រោះជំនួសនិយោជិតហើយ និយោជកអាចទាមទារសំណងពីនិយោជិតវិញបាន។

[31] ក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧, មាត្រា ៧៤៧ កថាខណ្ឌទី៣។

[32] សេចក្តីពន្យល់ក្រមរដ្ឋប្បវេណី, (ភ្នំពេញ៖សាលាភូមិន្ទរដ្ឋបាល,២០១២) ភាគ ៤,ទំព័រ ៤២។

## ២.៣. អំពើអនីត្យានុកូលរបស់នីតិបុគ្គល

នីតិបុគ្គល ជាអង្គភាពដែលមិនមែនជាមនុស្ស ឬជាអង្គការមួយដែលច្បាប់ឱ្យនិយមន័យយ៉ាងច្បាស់ ហើយចាត់ទុកថាជាបុគ្គលសំរាប់គោលបំណងនៃច្បាប់នោះតែប៉ុណ្ណោះ។[33] ផ្អែកតាមសទ្ទានុក្រមផ្អែករដ្ឋប្បវេណី ឆ្នាំ២០០៧ នីតិបុគ្គល ជាក្រុមមនុស្ស ឬមូលនិធិដែលមានបុគ្គលភាពគតិយុត្ត ហើយជាម្ចាស់នៃសិទ្ធិ និងកាតព្វកិច្ច។ នីតិបុគ្គល ធ្វើសកម្មភាពផ្សេងៗតាមរយៈរូបវន្តបុគ្គលដែលជាអ្នកតំណាង ឬអភិបាល។ អភិបាលជាអ្នកតំណាងឱ្យនីតិបុគ្គល។[34]

អំពើអនីត្យានុកូលរបស់នីតិបុគ្គល គឺសំដៅដល់អំពើគឺជាអំពើបំពានសិទ្ធ ឬផលប្រយោជន៍អ្នកដទៃដែលបង្កឡើងដោយអភិបាល ឬអ្នកតំណាង។ នៅពេលដែលអភិបាល ឬអ្នកតំណាងនៃនីតិបុគ្គលបានធ្វើអំពើខុសច្បាប់ នីតិបុគ្គលត្រូវតែទទួលខុសត្រូវទៅលើការខូចខាតដែលបានកើតឡើងពីអំពើរបស់អភិបាល ឬអ្នកតំណាង។[35]

### ២.៣.១. លក្ខខណ្ឌក្នុងការទទួលខុសត្រូវ

#### ២.៣.១.១. នីតិបុគ្គល

ការទទួលខុសត្រូវរបស់នីតិបុគ្គលក្នុងការសងការខូចខាត ត្រូវស្របតាមលក្ខខណ្ឌដូចខាងក្រោម៖

- អភិបាល ឬអ្នកតំណាងអនុវត្តសិទ្ធិក្នុងនាមជានីតិបុគ្គល
- អភិបាល ឬអ្នកតំណាងបានបង្កការខូចខាតដល់អ្នកដទៃដោយខុសច្បាប់ ដោយកំហុសចេតនា ឬកំហុសអចេតនា
- អំពើបំពានកើតឡើងក្នុងពេលអនុវត្តភារកិច្ច។[36]

**ឧទាហរណ៍៖** បុគ្គលិក **ក** ធ្វើការនៅក្នុងក្រុមហ៊ុន **ខ** ( ក្រុមហ៊ុនដឹកជញ្ជូនអ្នកដំណើរ) បានបើកបររថយន្តដឹកអ្នកដំណើរពីខេត្តបន្ទាយមានជ័យទៅរាជធានីភ្នំពេញ។ បុគ្គលិក **ក** បានបើករថយន្តដោយស្ថានភាពងងុយគេង ធ្វើឱ្យបើកបុករថយន្ត គ បណ្ដាលឱ្យខូចខាតជាខ្លាំងក្នុងកំឡុងពេលបំពេញការងារឱ្យក្រុមហ៊ុន **ខ** ។

---

[33] វចនានុក្រមតម្រាច្បាប់

[34] ក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧, មាត្រា៥៨។

[35] ក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧, មាត្រា ៧៤៨។

[36] កិច្ចប្រជុំក្រុមការងារជម្រុះលើកទី៣(សាលប្រជុំក្រសួងយុត្តិធម៌៖ ធ្នូ ២០១៥), ទំព័រ ១៦។

ក្នុងករណីខាងលើបានបង្ហាញឱ្យឃើញថា **ក** គឺជាបុគ្គលិកដឹកជញ្ជូនអ្នកតំណាងឱ្យក្រុមហ៊ុន **ខ** (នីតិបុគ្គល) បានប្រព្រឹត្តនូវកំហុសបើកបររថយន្តដឹកអ្នកដំណើរក្នុងស្ថានភាពងងុយគេង ទៅបុករថយន្ត **គ** ធ្វើឱ្យមានការខូចខាតជាខ្លាំង។

ដូចនេះហើយ ការខូចខាតដែលបង្កឡើងដោយបុគ្គលិក **ក** ទៅលើជនរងគ្រោះ **គ** គឺក្រុមហ៊ុន **ខ** ដែលជានីតិបុគ្គលជាអ្នកទទួលខុសត្រូវចំពោះការខូចខាតដែលបុគ្គល **ក** បានប្រព្រឹត្ត។

### ២.៣.១.២. អ្នកតំណាង ឬអភិបាល

អភិបាល ឬអ្នកដំណាងសំដៅដល់អង្គភាពមួយដើម្បីអនុវត្តកិច្ចការរបស់នីតិបុគ្គល។[37] ហើយអភិបាល ឬអ្នកតំណាង គឺជាអ្នកធ្វើសកម្មភាពផ្សេងៗសម្រាប់បម្រើផលប្រយោជន៍ឱ្យនីតិបុគ្គល។ ជាគោលការណ៍ នៅពេលដែលអភិបាលបានប្រព្រឹត្តកំហុសអ្វីមួយដែលទៅលើអ្នកដទៃ នីតិបុគ្គលគឺជាអ្នកទទួលខុសត្រូវនូវអំពើនោះ។[38] ដើម្បីឱ្យអ្នកតំណាង ឬអភិបាលទទួលខុសត្រូវនូវអំពើអនីត្យានុកូលត្រូវស្របតាមលក្ខខណ្ឌដូចខាងក្រោម៖

- ការខូចខាតកើតឡើងដោយអំពើរបស់អ្នកតំណាង ឬអភិបាល
- អ្នកតំណាង ឬអភិបាលបានប្រព្រឹត្តកំហុសចេតនា ឬអចេតនា
- ការខូចខាតកើតឡើងមិនមែនក្នុងកំឡុងពេលបំពេញការងារ
- កំហុសរបស់អ្នកតំណាង ឬអភិបាលមិនមានគោលដៅបម្រើផលប្រយោជន៍ដល់នីតិបុគ្គល។

**ឧទាហរណ៍**៖ លោក **ក** ជាអភិបាលនៅក្រុមហ៊ុនផលិតទឹកអប់មួយកន្លែង។ បន្ទាប់ពីបញ្ចប់ម៉ោងការងាររបស់គាត់ លោក **ក** បានទៅជួបជាមិត្តភក្តិរបស់គាត់នៅភោជនីយដ្ឋានមួយ។ នៅពេលទៅដល់ភោជនីយដ្ឋាន គាត់ត្រូវបើករថយន្តរបស់ទៅទុកនៅចំណតរថយន្ត។ នៅពេលនោះបានថយរថយន្តទៅប៉ះបុរសម្នាក់បណ្ដាលឱ្យរងរបួស។

ក្នុងអង្គហេតុខាងលើនេះ លោក **ក** ជាអភិបាលនៅក្នុងក្រុមហ៊ុនផលិតទឹកអប់។ លោក **ក** បានប្រព្រឹត្តនូវកំហុស ដោយថយរថយន្តទៅប៉ះបុរសម្នាក់បណ្ដាលឱ្យរងរបួស។ ក្រុមហ៊ុនផលិតទឹកអប់មិនត្រូវបានទទួលខុសត្រូវអំពើរបស់លោក **ក** ទេ ដោយហេតុថា លោក **ក** ដែលជាអភិបាលបានប្រព្រឹត្តកំហុសមិនមែនក្នុងម៉ោងការងារ និងកំហុសដែលកើតនោះមិនមែនក្នុងគោលដៅផ្ដល់ប្រយោជន៍ឱ្យក្រុមហ៊ុន។

---

[37] សន្ធានុក្រមផ្នែករដ្ឋប្បវេណីឆ្នាំ ២០០៧។

[38] ក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧, មាត្រា ៧៤៧ កថាខណ្ឌទី១។

### ២.៣.២. ការទទួលខុសត្រូវ

#### ២.៣.២.១. ការទទួលខុសត្រូវរបស់នីតិបុគ្គល

នីតិបុគ្គលត្រូវទទួលខុសត្រូវក្នុងការសងការខូចខាតដែលអភិបាល ឬអ្នកតំណាងឯទៀតបានបង្កដល់អ្នកដទៃដោយខុសច្បាប់ដោយកំហុសចេតនា ឬដោយកំហុសអចេតនាក្នុងការអនុវត្តភារកិច្ច។[39] កំហុសរបស់អ្នកតំណាង ឬអភិបាលជាហេតុនាំឱ្យនីតិបុគ្គលទទួលខុសត្រូវ ទោះបីជាកំហុសជាកំហុសចេតនាក្តី ឬជាកំហុសអចេនាក្តី។ កិច្ចការរបស់អភិបាល ឬអ្នកតំណាងសម្រាប់នីតិបុគ្គលសកម្មភាពរបស់អភិបាល ឬអ្នកតំណាងក្នុងពេលអនុវត្តកិច្ចការ គឺជាប្រយោជន៍របស់នីតិបុគ្គល។ នីតិបុគ្គលទទួលខុសត្រូវ ចំពោះការបំពានដែលកើតមានឡើងពេលអនុវត្តកិច្ចការ។ នីតិបុគ្គទទួលបានផលប្រយោជន៍ ពីសកម្មភាពរបស់អភិបាល ឬអ្នកតំណាងដែលនាំនីតិបុគ្គលត្រូវទទួលខុសត្រូវសងសំណងការខូចខាត។ ការទទួលខុសត្រូវចំពោះអំពើអនីត្យានុកូលរបស់នីតិបុគ្គលនេះដែរ បើយោងទៅតាមមាត្រា ៧៤៨ នៃក្រមរដ្ឋប្បវេណី ឃើញថាមានលក្ខណៈប្រហាក់ប្រហែលទៅនិងបញ្ញត្តិនៃការទទួលខុសត្រូវរបស់និយោកជកផងដែរ ព្រោះថាវាស្ថិតក្នុងស្ថានភាពមួយដូចគ្នាដែលកើតចេញពីបុគ្គលដែលធ្វើការនៅក្នុងរោងចក្រសហគ្រាស ឬក្រុមហ៊ុនណាមួយ។ ប៉ុន្តែវាមានភាពខុសគ្នាមួយចំនួនដូចជា៖

- ក្នុងករណីអំពើអនីត្យានុកូលរបស់នីតិបុគ្គល អ្នកប្រព្រឹត្តអំពើបំពានគឺត្រូវបានកម្រិតចំពោះសមាជិកនាយក ឬអ្នកតំណាងស្របច្បាប់របស់នីតិបុគ្គលនោះចំណែកក្នុងករណីនៃការទទួលខុសត្រូវរបស់និយោជកគ្មានការកំណត់បែបនេះទេ តែជាការទទួលខុសត្រូវរបស់រូបវន្តបុគ្គលម្នាក់ដែលជានិយោជកចំពោះអំពើរបស់រូបវន្តបុគ្គលម្នាក់ទៀតដែលជានិយោជិត។
- នីតិបុគ្គលមិនអាចធ្វើការតវ៉ាដើម្បីរួចផុតពីការទទួលខុសត្រូវ ដូចជាការតវ៉ានៅក្នុងករណីនៃការទទួលខុសត្រូវរបស់បុគ្គលដែលត្រួតពិនិត្យជំនួសនិយោជកដោយអះអាងពីការគ្រប់គ្រងត្រឹមត្រូវបានឡើយ ។

ចំពោះអំពើអនីត្យានុកូលដែលបានប្រព្រឹត្តដោយអ្នកតំណាងរបស់នីតិបុគ្គល គឺសាមីខ្លួនអ្នកតំណាងនោះជាអ្នកទទួលខុសត្រូវ ហើយក្រៅពីនេះនីតិបុគ្គលក៏ត្រូវទទួលខុសត្រូវផងដែរ។ ពាក់ព័ន្ធនឹងការទទួលខុសត្រូវចំពោះអំពើអនីត្យានុកូលរបស់នីតិបុគ្គលពុំមានបញ្ញត្តិលើកលែង ដូចការទទួលខុសត្រូវរបស់និយោជក

[39] ក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧, មាត្រា ៧៤៨ កថាខណ្ឌទី១។

ពោលគឺមានភាពតឹងតែងជាងដោយហេតុថាទំនាក់ទំនងរវាងអ្នកតំណាងនិងនីតិបុគ្គល គឺមានភាពជិតស្និទ្ធណាស់។ លើសពីនេះទៅទៀតអំពើរបស់ស្ថាប័នតំណាង គឺជាអំពើរបស់នីតិបុគ្គលនោះតែម្តង។[40]

### ២.៣.២.២. ការទទួលខុសត្រូវរបស់អ្នកតំណាង ឬអភិបាល

ជាទូទៅ នៅពេលដែលមានអំពើអនីត្យានុកូលកើតឡើង បុគ្គលដែលបានប្រព្រឹត្តកំហុសដែលបំពានសិទ្ធិ ឬផលប្រយោជន៍អ្នកដទៃត្រូវទទួលខុសត្រូវនូវទង្វើដែលខ្លួនបានធ្វើ។ ក៏ដូចជា អភិបាល ឬអ្នកតំណាងផងដែរនៅពេលប្រព្រឹត្តនៅកំហុសទោះបីកំហុសនៅកើតឡើងដោយចេតនា ឬអចេតនា អ្នកតំណាង ឬអភិបាលត្រូវទទួលខុសត្រូវនូវអំពើនោះ បើកំហុសដែលកើតឡើងនោះមិនមែនស្ថិតនៅក្នុងពេលបំពេញការងារ ឬកំហុសរបស់អ្នកតំណាង ឬអភិបាលមិនមានគោលដៅបម្រើផលប្រយោជន៍ដល់នីតិបុគ្គល។

**ឧទាហរណ៍៖** លោក ខ ជាអភិបាលនៅក្រុមហ៊ុនផលិតរថយន្ត។ បន្ទាប់បំពេញការងាររបស់ខ្លួនរួចរាល់ លោក ខ បានបើករថយន្តត្រឡប់ទៅផ្ទះរបស់គាត់។ នៅពេលទៅដល់ផ្ទះរបស់គាត់ លោក ខ បានទាស់សម្តីជាមួយអ្នកជិតខាងរបស់គាត់ មូលហេតុមកពីការចតរថយន្តឆ្លងបរិវេណដី។ ដោយសារកំហឹងធ្វើឱ្យលោក ខ ជ្រុលដៃច្រានអ្នកជិតខាងឱ្យដួលបណ្តាលឱ្យមានរបួស។

តាមអង្គហេតុខាងលើ កំហុសមិនមែនកើតឡើងនៅក្នុងពេលបំពេញការងារ ហើយជាកំហុសរបស់លោក ខ ។ ដូចនេះ លោក ខ ត្រូវទទួលខុសត្រូវនូវកំហុសរបស់ខ្លួន។

### ២.៣.៣. ការទាមទារសំណងត្រឡប់មកវិញ

**នីតិបុគ្គល** អាចទាមទារសំណងពីអ្នកតំណាងដែលបានប្រព្រឹត្តអំពើបង្កការខូចខាតនោះបាន។ [41] ដើម្បីពិចារណាអំពីការទាមទារសំណងការខូចខាត ៖

- កំហុសរបស់អភិបាល ឬអ្នកតំណាងនីតិបុគ្គល
- នីតិបុគ្គល ជាអ្នកសងទៅឱ្យជនរងគ្រោះពីអំពើដែលបង្កឱ្យមានការខូចខាត
- អ្នកតំណាងនីតិបុគ្គលធ្វេសប្រហែសគ្មានការប្រុងប្រយ័ត្ន។

**ឧទាហរណ៍៖** បុគ្គលិកឈ្មោះ **ក** នៅក្នុងក្រុមហ៊ុន **ខ** បានភ្លេចស្លាកសញ្ញាសម្គាល់ប្រុងប្រយ័ត្នពេលកំពុងជូតឥដ្ឋធ្វើឱ្យ **គ** រអិលដួលនិងរងរបួស។ តាមអង្គហេតុនេះ បុគ្គលិក **ក** ជាតំណាងរបស់នីតិបុគ្គល **ខ** ក្នុងការអនុវត្តភារកិច្ច ដូចនេះ នីតិបុគ្គល **ខ** គឺជាអ្នកទទួលខុសត្រូវក្នុងការសងសំណងខូចខាត។ នៅពេលសង

[40] សេចក្តីពន្យល់ក្រមរដ្ឋប្បវេណី, (ភ្នំពេញ៖សាលាភូមិន្ទរដ្ឋបាល,២០១២) ភាគ៤, ទំព័រ៤៣។

[41] ក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧, មាត្រា ៧៤៨។

ការខូចខាតរួចរាល់ហើយនីតិបុគ្គល **ខ** អាចទាមទារសំណងពីអ្នកតំណាង **ក** ដែលបានប្រព្រឹត្តអំពើដោយការធ្វេសប្រហែសបង្កឱ្យមានការខូចខាតបាន។

## ២.៤. អំពើអនីត្យានុកូលរបស់មន្ត្រីរាជការ

បុគ្គលម្នាក់ៗត្រូវទទួលខុសត្រូវ នូវទង្វើដែលបានធ្វើឱ្យមានការខូចខាតដល់អ្នកដល់អ្នកដទៃ។ ហើយមន្ត្រីរាជការក៏ត្រូវទទួលខុសត្រូវទង្វើដែលប៉ះពាល់ដល់ប្រយោជន៍អ្នកដទៃដែលកើតឡើងក្នុងការបំពេញភារកិច្ចរបស់ខ្លួន។ រដ្ឋ ឬស្ថាប័នសាធារណៈក៏ត្រូវទទួលខុសត្រូវនូវអំពើរបស់មន្ត្រីរាជការដែលធ្វើឱ្យមានការខូចខាតប្រយោជន៍របស់អ្នកដទៃក្នុងពេលអនុវត្តភារកិច្ច។

មន្ត្រីរាជការដែលទទួលបាននូវអំណាចសាធារណៈរបស់រដ្ឋ ឬស្ថាប័នសាធារណៈបានបង្កការខូចខាតដល់អ្នកដទៃដោយខុសច្បាប់ដោយកំហុសចេតនា ឬកំហុសអចេតនាក្នុងការអនុវត្តភារកិច្ចរបស់ខ្លួននោះ រដ្ឋ ឬស្ថាប័នសាធារណៈត្រូវទទួលខុសត្រូវក្នុងការសងការខូចខាតនោះ។[42] ក្នុងករណី បើកម្រិតនៃការបំពានករណីកិច្ចរបស់មន្ត្រីរាជការក្នុងការជៀសវាងនូវលទ្ធផលមានភាពធ្ងន់ធ្ងរ។ រដ្ឋ ឬស្ថាប័នសាធារណៈអាចទាមទារសំណងពីមន្ត្រីរាជការនោះបាន។

អ្នករាជការសាធារណៈ គឺបុគ្គលដែលបម្រើការងារនៅក្នុងស្ថាប័ននីតិប្បញ្ញត្តិ ស្ថាប័ននីតិប្រតិបត្តិ ឬស្ថាប័នតុលាការដែលត្រូវបានតែងតាំងដោយលិខិតបទដ្ឋានគតិយុត្តទោះជាអចិន្ត្រៃយ៍ ឬបណ្តោះអាសន្នក្តី ទោះជាបាន ឬមិនបានទទួលប្រាក់ឈ្នួលក្តី ដោយមិនគិតពីឋានៈ អាយុរបស់បុគ្គលនោះឡើយ។[43]

យោងតាមមាត្រា៣០ នៃរដ្ឋធម្មនុញ្ញឆ្នាំ ១៩៩៣ បានចែងថា ពលរដ្ឋកម្ពុជាមានសិទ្ធិស្មើគ្នាចំពោះមុខច្បាប់។ បន្ថែមពីនេះ មាត្រា៣៩ នៃរដ្ឋធម្មនុញ្ញបានចែងថា ពលរដ្ឋទាំងឡាយត្រូវរស់នៅតាមរបៀបសង្គម ហើយរួមចំណែកការពារទ្រព្យសម្បត្តិសាធារណៈ។ ពលរដ្ឋមានសិទ្ធិបរិហារ ប្តឹងតវ៉ា ឬប្តឹងទារសំណងជួសជុលការខូចខាតដែលបណ្តាលមកពីអំពើខុសច្បាប់របស់ អង្គការរដ្ឋ របស់អង្គការសង្គម និងរបស់បុគ្គលិកនៃអង្គការទាំងនោះ ក្នុងពេលបំពេញភារកិច្ចរបស់ខ្លួន។ តាមអត្ថន័យនេះ នៅពេលមន្ត្រីរាជការបង្កការខូចខាតដល់អ្នកដទៃនៃជនរងគ្រោះអាចប្តឹងតវ៉ា ឬប្តឹងទារសំណងជួសជុលការខូចខាតដែលបណ្តាលមកពីអំពើខុសច្បាប់របស់ អង្គការរដ្ឋ របស់អង្គការសង្គម និងរបស់បុគ្គលិកនៃអង្គការទាំងនោះក្នុងពេលបំពេញភារកិច្ចរបស់ខ្លួន។

[42] ក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧, មាត្រា ៧៤៩ កថាខណ្ឌទី១។

[43] ក្រមព្រហ្មទណ្ឌឆ្នាំ ២០០៩, មាត្រា ៣០។

### ២.៤.១. លក្ខខណ្ឌក្នុងការទទួលខុសត្រូវ

ដើម្បីឱ្យស្ថាប័នរដ្ឋទទួលខុសត្រូវអំពីអនីត្យានុកូលរបស់មន្ត្រីរាជការលុះត្រាតែអំពើនោះបំពេញនូវលក្ខខណ្ឌដូចជា៖

ក- បុគ្គលប្រព្រឹត្តអំពើអនីត្យានុកូលត្រូវជាមន្ត្រីរាជការ

ខ- បង្កការខូចខាតដល់អ្នកដទៃដោយខុសច្បាប់ ដោយកំហុសចេតនា ឬ ដោយកំហុសអចេតនា

គ- ប្រព្រឹត្តអំពើក្នុងពេលទទួលនូវការអនុវត្តអំណាចសាធារណៈ ។[44]

លក្ខខណ្ឌ (គ) គឺជាលក្ខខណ្ឌមួយដែលតម្រូវឱ្យមានជាដាច់ខាត ដើម្បីឱ្យសកម្មភាពឯកជនរបស់មន្ត្រីរាជការមិនបណ្តាលឱ្យមានការទទួលខុសត្រូវរបស់រដ្ឋ ។

**ឧទាហរណ៍**៖ ទាហ៊ានម្នាក់ នៅពេលកំពុងបំពេញភារកិច្ចការពារព្រំដែនដែលកំពុងមានការផ្ទុះអាវុធកើតឡើង។ ពេលដែលកំពុងបាញ់ការពារខ្លួនតទល់ជាមួយខ្មាំងសត្រូវ ពេលនោះគ្រាប់កាំភ្លើងក៏បានបាញ់ចំប្រជាពលរដ្ឋម្នាក់ដែលបានស្ថិតក្នុងកន្លែងកើតហេតុនោះ។

តាមមរយៈអង្គហេតុខាងលើបានបង្ហាញឱ្យឃើញថា ទាហ៊ាន ជាមន្ត្រីរាជការបានប្រព្រឹត្តនូវកំហុសបាញ់ចំជនរងគ្រោះម្នាក់ក្នុងកំឡុងពេលបំពេញភារកិច្ច

### ២.៤.២. ការទទួលខុសត្រូវរបស់មន្ត្រីរាជការ

បើមន្ត្រីរាជការដែលទទួលការអនុវត្តនូវអំណាចសាធារណៈរបស់រដ្ឋ ឬស្ថាប័នសាធារណៈ បានបង្កការខូចខាតដល់អ្នកដទៃដោយខុសច្បាប់ដោយកំហុសចេតនា ឬដោយកំហុសអចេតនាក្នុងការអនុវត្តភារកិច្ចរបស់ខ្លួននោះ រដ្ឋ ឬស្ថាប័នសាធារណៈត្រូវទទួលខុសត្រូវក្នុងការសងការខូចខាតនោះ។ មន្ត្រីសាធារណៈផ្ទាល់មិនទទួលខុសត្រូវចំពោះអំពើបំពានទេ ប៉ុន្តែមានតែរដ្ឋប៉ុណ្ណោះ ដែលត្រូវទទួលខុសត្រូវចំពោះអំពើអនីត្យានុកូលនៅពេលអនុវត្តនូវអំណាចសាធារណៈរបស់រដ្ឋ ឬ ស្ថាប័នសាធារណៈ។[45]

**ឧទាហរណ៍**៖ មន្ត្រីនគរបាលម្នាក់កំពុងជិះម៉ូតូដេញចាប់ជនល្មើសដែលកំពុងរត់គេចខ្លួនពីការតាមចាប់។ ពេលកំពុងជិះម៉ូតូដេញចាប់នោះក៏បានជ្រុលចង្កូតទៅបុកនារីម្នាក់ដែលកំពុងដើរឆ្លងកាត់ផ្លូវបណ្តាលឱ្យនារីរងគ្រោះរបួសជាទម្ងន់។ ក្នុងករណីនេះ ដោយមន្ត្រីនគរបាលនោះបានប្រព្រឹត្តកំហុសធ្វើឱ្យនារីម្នាក់របួសក្នុងកំឡុងពេលដែលមន្ត្រីនគរបាលនោះកំពុងអនុវត្តភារកិច្ច។ ដូចនេះមន្ត្រីនគរបាលនោះផ្ទាល់មិនទទួលខុស

---

[44] ក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧, មាត្រា ៧៤៩ កថាខណ្ឌទី១។

[45] ដដែល។

ត្រូវចំពោះអំពើបំពានទេ ប៉ុន្តែមានតែរដ្ឋប៉ុណ្ណោះ ដែលត្រូវទទួលខុសត្រូវចំពោះអំពើអនីត្យានុកូលនៅពេលអនុវត្តនូវអំណាចសាធារណៈរបស់រដ្ឋ។

### ២.៤.៣. ការទាមទារសំណង

បើរដ្ឋ ឬស្ថាប័នសាធារណៈបានសងសំណងការខូចខាតទៅជនរងគ្រោះរួចហើយនោះរដ្ឋ ឬស្ថាប័នសាធារណៈអាចទាមទារសំណងពីមន្ត្រីរាជការនោះបាន។

ការទាមទារនេះគឺ មានគោលបំណង៖

- ដើម្បីការពារ ឬជៀសវាងនូវអំពើអនីត្យានុកូលកើតឡើងម្តងទៀត
- ដើម្បីកម្រិតនៃការបំពាន ឬដាក់កំហិតដល់មន្ត្រីរាជការដើម្បីឱ្យមានការប្រុងប្រយ័ត្នក្នុងពេលអនុវត្តភារកិច្ច
- ដើម្បីទប់ស្កាត់ការខូចខាតដែលកើតដោយមន្ត្រីរាជការក្នុងពេលអនុវត្តមានភាពធ្ងន់ធ្ងរ។[46]

រដ្ឋ ឬស្ថាប័នសាធារណៈអាចទាមទារសំណងបានតែនៅពេលដែលមន្ត្រីរាជការបានបំពានករណីយកិច្ចធ្ងន់ធ្ងរ ។ ចំណុចខុសគ្នាទៅនឹងការទទួលខុសត្រូវរបស់និយោជកគឺ ពុំមានបញ្ញត្តិលើកលែងសម្រាប់រដ្ឋ ឬអង្គការសង្គមទេហើយការទាមទារសំណងដោយរដ្ឋ ឬដោយអង្គការសង្គមចំពោះសាមីខ្លួនមន្ត្រីរាជការអាចធ្វើទៅបានតែក្នុងករណីដែលមានការធ្វើសកម្មភាពផ្ទុយនឹងករណីយកិច្ចធ្ងន់ធ្ងរតែប៉ុណ្ណោះ។[47]

---

[46] ក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧, មាត្រា ៧៤៩។

[47] សេចក្តីពន្យល់ក្រមរដ្ឋប្បវេណី, (ភ្នំពេញ៖សាលាភូមិន្ទរដ្ឋបាល,២០១២) ភាគ៤, ទំព័រ៤៤។

# ជំពូកទី៣

# ការជួសជុលព្យសនកម្ម

# ជំពូកទី៣
# ការជួសជុលព្យសនកម្ម

## ៣.១. ការគណនាការខូចខាត

អំពើអនីត្យានុកូលកើតមានឡើងជាហេតុនាំឲ្យមានការបង្កើតសិទ្ធិទាមទារសំណងខូចខាតពីសំណាក់ជនរងគ្រោះហើយអ្នកប្រព្រឹត្ត ឬអ្នកទទួលខុសត្រូវ ត្រូវមានកាតព្វកិច្ចសងការខូចខាតនោះ។ ហើយការគណនាការខូចខាតដែលកើតឡើងពីអំពើអនីត្យានុកូលគឺ ការខូចខាតជាទ្រព្យសម្បត្តិ ការខូចខាតសតិអារម្មណ៍ ការខូចខាតលើរូបកាយ ការបំពានលើជីវិត ។

### ៣.១.១. ការខូចខាតជាទ្រព្យសម្បត្តិ

ក្នុងការគណនាចំនួនទឹកប្រាក់នៃភាពខុសគ្នា រវាងស្ថានភាពនៃទ្រព្យសម្បត្តិដែលត្រូវបានសន្មតថានឹងមានប្រសិនបើគ្មានអំពើអនីត្យានុកូល និងស្ថានភាពនៃទ្រព្យសម្បត្តិ ជាក់ស្តែងក្រោយពេលដែលអំពើអនីត្យានុកូលបានកើតឡើងត្រូវបានវាយតម្លៃដោយប្រើប្រាស់នូវស្ថិតិ និងឯកសារផ្សេងទៀត ។[48]

ចំពោះវត្ថុបានបាក់បែកដោយអំពើអនីត្យានុកូល អ្នករងគ្រោះអាចទាមទារសំណងជាតម្លៃនៃវត្ថុដែលបាក់បែក ឬសោហ៊ុយជួសជុលវត្ថុនោះ។ [49] ប្រសិនបើមូលហេតុបង្កឱ្យមានការខូចខាតបានបង្កឱ្យមានការបាត់បង់នូវផលចំណេញដែលត្រូវទទួលបានពីការលក់វត្ថុនោះការបាត់បង់នូវផលចំណេញនេះត្រូវទទួលស្គាល់ថាជាការខូចខាត ។[50]

### ៣.១.២. ការខូចខាតសតិអារម្មណ៍

ការគណនាចំនួនទឹកប្រាក់នៃការខូចខាតសតិអារម្មណ៍ ដោយសារអំពើអនីត្យានុកូលចំនួនទឹកប្រាក់នៃជម្ងឺចិត្តត្រូវបានវាយតម្លៃដោយគិតពិចារណានូវស្ថានភាពផ្សេងៗដូចជា៖

- កម្រិតនៃកំហុសចេតនា ឬអចេតនារបស់អ្នកប្រព្រឹត្តអំពើបំពាន ប្រភេទ និងកម្រិតនៃការរងគ្រោះ
- អំពើរបស់អ្នកប្រព្រឹត្តក្រោយពេលកើតមានអំពើបង្កឱ្យមានការរងគ្រោះនោះ ។[51]

---

[48] ក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧, មាត្រា ៧៥៨ កថាខណ្ឌទី១។

[49] ក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧, មាត្រា ៧៥៩។

[50] ឯកឧត្តម ហ៊ី សោភា, មេរៀនស្តីពីអំពើអនីត្យានុកូល, ទំព័រ ៧៩។

[51] ក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧, មាត្រា ៧៥៨ កថាខណ្ឌទី២។

### ៣.១.៣. ការខូចខាតលើរូបកាយ

បើមានការបំពានលើរូបរាងកាយ ដោយអំពើអនីត្យានុកូលជនរងគ្រោះអាចទាមទារសំណងនៃការខូចខាតលើទ្រព្យសម្បត្តិ និងការខូចខាតសតិអារម្មណ៏ដែលបានកើតឡើងចំពោះខ្លួន។

ការខូចខាតលើទ្រព្យសម្បត្តិ រួមមានៈ

- សោហ៊ុយព្យាបាលដែលបានចំណាយហើយ
- សោហ៊ុយព្យាបាល ដែលប្រមាណថានឹងត្រូវចំណាយនាពេលអនាគត
- ប្រាក់ចំណូល ដែលមិនអាចទទួលបាននៅពេលកំពុងព្យាបាល
- ប្រាក់ចំណូលដែលមិនអាចទទួលបាននៅពេលអនាគត ដោយសារ ផលវិបាក ដែលបន្សល់ក្រោយពីការព្យាបាល។[52] ក្នុងចំណុចនេះ ពេលខ្លះគឺមានការលំបាកនឹងគណនាពីចំនួនប្រាក់ចំណូលដែលអាចទទួលបាននៅពេលអនាគតជាពិសេសនៅក្នុងករណីដែលជនរងគ្រោះមិនមានការងារធ្វើនៅពេលអំពើអនីត្យានុកូលបានកើតឡើង។

ការខូចខាតសតិអារម្មណ៍ក្នុងករណីនេះ ប្រាក់សំណងជំងឺចិត្តនឹងត្រូវកំណត់ដោយផ្អែកតាមកម្រិតនៃការរងរបួស និងផលវិបាកដែលបន្សល់ទុកដោយរួមបញ្ចូលទាំងការឈឺចាប់ផ្នែកសតិអារម្មណ៍នៅពេលព្យាបាល និងពេលអនាគតទៀតផង។[53]

### ៣.១.៤. ការបំពានលើជីវិត

បើជនរងគ្រោះទទួលមរណភាពដោយអំពើអនីត្យានុកូល អ្នករងគ្រោះអាចទទួលសិទ្ធិទាមទារសំណងចំពោះការខូចខាតលើទ្រព្យសម្បត្តិ និងការខូចខាតសតិអារម្មណ៍ដែលបានកើតឡើងចំពោះខ្លួនរហូតដល់មរណភាព។ ការខូចខាតលើទ្រព្យសម្បត្តិរួមបញ្ចូលទាំងៈ

- សោហ៊ុយព្យាបាល និងសោហ៊ុយចំណាយផ្សេងទៀតដែលជនរងគ្រោះបានបង់ ឬមានករណីយកិច្ចត្រូវបង់ចាប់ពីក្រោយអំពើបង្កឱ្យមានការរងគ្រោះរហូតដល់ពេលទទួលមរណភាព
- ប្រាក់ចំណូលដែលជនរងគ្រោះមិនបានទទួល ចាប់ពីក្រោយអំពើបង្កឱ្យមានការរងគ្រោះរហូតដល់ពេលទទួលមរណភាព។

[52] ក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧, មាត្រា ៧៦១។

[53] សេចក្តីពន្យល់ក្រមរដ្ឋប្បវេណី, (ភ្នំពេញៈសាលាភូមិន្ទរដ្ឋបាល,២០១២) ភាគ៤, ទំព័រ៣៥។

បន្ថែមពីនេះទៅទៀត បើបុគ្គលដែលមានករណីយកិច្ចផ្តល់អាហារកាតព្វកិច្ចដោយច្បាប់ ទំនៀមទម្លាប់ ឬដោយកិច្ចសន្យាបានទទួលមរណភាពដោយអំពើអនីត្យានុកូល បុគ្គលដែលទទួលជីវព្រឹត្តិអាចទាមទារសំណងការខូចខាតលើទ្រព្យសម្បត្តិដែលបានកើតឡើងចំពោះខ្លួនដោយសារមរណភាពរបស់ជនរងគ្រោះ។

ការខូចខាតលើទ្រព្យសម្បត្តិ ត្រូវរួមបញ្ចូលទាំង៖

- ប្រាក់ជីវព្រឹត្តិដែលលែងបានទទួលដោយសារមរណភាពនៃជនរងគ្រោះ
- សោហ៊ុយដែលចេញជំនួសជនរងគ្រោះ
- សោហ៊ុយធ្វើបុណ្យសព ។

បើជនរងគ្រោះទទួលមរណភាព ដោយអំពើអនីត្យានុកូល សហព័ទ្ធ ញាតិនៅក្នុង១ថ្នាក់ និងញាតិដែលរស់នៅជាមួយជនរងគ្រោះអាចទាមទារសំណងនៃការខូចខាតសតិអារម្មណ៍ដែលបានកើតឡើងដោយសារមរណភាពរបស់ជនរងគ្រោះបាន។[54]

## ៣.២. គោលការណ៍នៃការសងការខូចខាត

នៅពេលដែលមានអនីត្យានុកូលមួយត្រូវបានកើតឡើងមកនោះវានឹងភ្ជាប់ជាមួយនិងព្យសនកម្មផងដែរ។ ដូចនេះនៅពេលដែលមានព្យសនកម្មបែបនេះហើយគឺតម្រូវឲ្យមានប្រធាននៃអំពើនោះ គឺមានន័យត្រូវតែមានអ្នកទទួលខុសត្រូវចំពោះព្យសនកម្មដែលបានកើតឡើងតាមរយៈការជួលជុលព្យសនកម្ម។ ជាមួយគ្នានេះការជួសជុលព្យសនកម្មអាចធ្វើឡើងតាមរូបភាពមួយចំនួនដូចជា ការសងការខូចចាតជាប្រាក់ ការទាមទារឲ្យធ្វើបដិទានវិញ និងការហាមឃាត់មិនឲ្យធ្វើសកម្មភាពជាកំណត់។

### ៣.២.១. ការសងការខូតខាតជាប្រាក់

អំពើអនីត្យានុកូល គឺជារបបឲ្យសងសំណងលើការខូតខាតក្នុងករណីដែលបំពានសិទ្ធិ និងផលប្រយោជន៍របស់អ្នកដទៃដោយខុសច្បាប់ដោយកំហុសចេតនាក្តី ឬអចេតនាក្តី។ ហេតុនេះហើយនៅពេលដែលមានអំពើអនីត្យានុកូលមួយត្រូវបានកើតឡើងហើយ គឺប៉ះប៉ូវមកវិញដោយការនេះប៉ះប៉ូវទៅលើព្យសនកម្មនេះតាមរយៈការសងការខូតខាត។ ជាគោលការណ៍ សំណងនៃការខូតខាតត្រូវសងជាប្រាក់។[55] គោលការណ៍សងការខូតខាតជាប្រាក់ គឺជាមធ្យោបាយមួយដែលសមស្របនឹងសមរម្យផងដែរដើម្បីមានភាពងាយស្រួលចំពោះអ្នកទទួលខុសត្រូវ និងជនរងគ្រោះ។

[54] ក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧, មាត្រា ៧៦០។

[55] ក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧, មាត្រា ៧៥៧ កថាខណ្ឌទី១។

### ៣.២.២. ការទាមទារឲ្យធ្វើបដិទាន

ចំពោះអំពើអនីត្យានុកូលដែលបានកើតមានឡើងជនរងគ្រោះអាចទាមទារឲ្យធ្វើបដិទាន គឺមានន័យថាអ្នកទទួលខុសត្រូវទៅលើការជួសជុលព្យសនកម្ម គឺនឹងធ្វើឲ្យវាត្រឡប់ទៅរកស្ថានភាពដើមមកវិញបាននៅក្នុងករណីដែលមិនអាចសង្គ្រោះត្រឹមត្រូវដោយសំណងជាប្រាក់ ជនរងគ្រោះអាចទាមទារអោយធ្វើបដិទាន ឬអាចទាមទារឲ្យហាមឃាត់មិនឲ្យធ្វើអំពើណាមួយបាន។[56] នៅក្នុងឃ្លានេះមានន័យថានៅក្នុងករណីដែលលក្ខខណ្ឌនៃអំពើអនីត្យានុកូលត្រូវបានបំពេញស្របទៅតាមច្បាប់កំណត់ហើយនោះមានន័យថាអំពើអនីត្យានុកូលត្រូវបានលេចជារូបភាពឡើងមកជាមួយគ្នានេះការជួសជុលព្យសនកម្មនៃអំពើនេះជាគោលការណ៍ គឺត្រូវសំណងការខូចខាតជាប្រាក់ ប៉ុន្តែជាករណីពិសេសមួយនៅក្នុងចំណុចនេះ បើជនរងគ្រោះ ឬបុគ្គលដែលត្រូវទទួលខុសត្រូវទៅលើអំពើអនីត្យានុកូលពុំមានប្រាក់សងលើការខូចខាតនោះទេ នោះជនរងគ្រោះ ឬបុគ្គលដែលត្រូវទទួលខុសត្រូវអំពើនេះអាចធ្វើបដិទានទៅឲ្យជនរងគ្រោះវិញបានផងដែរ ហើយការធ្វើបដិទាននេះគឺជនរងគ្រោះអាចទាមទារបានតែត្រឹមកម្រិតដែលខូចខាតតែប៉ុណ្ណោះ។

### ៣.២.៣. ការហាមឃាត់មិនឲ្យធ្វើសកម្មភាពជាកំណត់

ចំពោះការបរិហារកេរ្តិ៍ ក្រៅពីសំណងនៃការខូចខាត ជនរងគ្រោះអាចទាមទារ វិធានការស្តារកិត្តិយសឡើងវិញ ដូចជាការផ្សព្វផ្សាយសេចក្តីអភ័យទោសជាសាធារណៈបាន។ នេះគឺជាការជួសជុលការខូចខាតដែលមានលក្ខណៈពិសេសមួយទៀតក្នុងចំណោមការសងការខូតខាតផ្សេងៗទៀតផងដែរ។[57]

## ៣.៣. ការបន្ថយសំណងនៃការខូតខាត

វិសាលភាពនៃសំណងការខូចខាតដែលកើតចេញពីអំពើអនីត្យានុកូល ត្រូវធ្វើការវាយតម្លៃជាប្រាក់នូវការខូចខាតនៃទ្រព្យសម្បត្តិ ឬការខូចខាតខាងផ្លូវចិត្តជាដើមដែលតម្រូវឱ្យសងសំណង។ ប៉ុន្តែមានករណីដែលចំនួនទឹកប្រាក់មួយចំនួនត្រូវកាត់បន្ថយពីសំណងការខូចខាតដោយឈរលើទស្សនៈយុត្តិធម៌។ ការទូទាត់ប្រាក់ចំណេញ និងខាតការទូទាត់នូវកំហុស គឺជាឧទាហរណ៍ដែលការកាត់បន្ថយនូវសំណងការខូចខាតត្រូវបានចាត់ទុកថាមានភាពចាំបាច់ ។[58]

---

[56] ក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧, មាត្រា ៧៥៧ កថាខណ្ឌទី២។

[57] ក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧, មាត្រា ៧៥៧ កថាខណ្ឌទី៣។

[58] សេចក្តីពន្យល់ក្រមរដ្ឋប្បវេណី, (ភ្នំពេញ៖សាលាភូមិន្ទរដ្ឋបាល,២០១២) ភាគ៤, ទំព័រ៣៧។

### ៣.៣.១. ការទូទាត់ប្រាក់ចំណេញ និងខាត

ប្រសិនបើ ជនរងគ្រោះបានទទួលផលចំណេញដោយសារអំពើអនីត្យានុកូលចំនួនប្រាក់ចំណេញនោះត្រូវដកចេញនៅពេលដែលធ្វើការគណនាចំនួនទឹកប្រាក់នៃសំណងការខូចខាត ។[59]

ករណីនេះគឺមានភាពចាំបាច់ពីព្រោះគោលបំណងនៃការទទួលខុសត្រូវខាងអំពើអនីត្យានុកូល គឺជាការទទួលបានមកវិញនូវអ្វីដែលបានបាត់បង់ពីការរងរបួសចំពោះស្ថានភាពដែលត្រូវបានសន្មត់ថាមានប្រសិនបើអំពើអនីត្យានុកូលមិនបានកើតមានឡើយ។ មានន័យថា ជនរងគ្រោះមិនត្រូវទទួលរងនូវការបាត់បង់ ឬទទួលផលចំណេញបន្ទាប់ពីទទួលបានមកវិញហើយនោះទេ។

ឧទាហរណ៍ដែលកើតមានជាញឹកញាប់នៃការទូទាត់ប្រាក់ចំណេញ និងខាត គឺសោហ៊ុយចំណាយសម្រាប់ជីវភាពរស់នៅ ។

ក្នុងករណីនៃការស្លាប់ដោយសារគ្រោះថ្នាក់ចរាចរ សន្តតិជនរបស់ជនរងគ្រោះអាចទាមទារសំណងការខូចខាតចំពោះប្រាក់ដែលជនរងគ្រោះអាចរកបាននៅពេលដែលមានជីវិតរស់នៅប្រសិនបើគ្មានគ្រោះថ្នាក់ចរាចរ ប៉ុន្តែមិនមែនអាចទាមទារគ្រប់ចំនួនបានទេពីព្រោះជនរងគ្រោះអាចទទួលបានប្រាក់ឈ្នួលប៉ុន្តែជនរងគ្រោះក៏មិនអាចជួយចំណាយសោហ៊ុយសំរាប់ជីវភាពរស់នៅទេ។

ហេតុដូច្នេះសោហ៊ុយសំរាប់ជីវភាពរស់នៅបែបនេះត្រូវដកចេញ ដើម្បីកុំឱ្យសន្តតិជនរបស់ជនរងគ្រោះអាចទទួលផលប្រយោជន៍បានច្រើនជាងដែលគាត់អាចទទួលបានប្រសិនបើអំពើអនីត្យានុកូលមិនបានកើតមានឡើងនោះ ។[60]

### ៣.៣.២. ការទូទាត់កំហុស

បើកំហុសរបស់ជនរងគ្រោះ ឬកំហុសរបស់អ្នកដែលមានករណីយកិច្ច ត្រូវត្រួតពិនិត្យជនរងគ្រោះបានរួមចំណែកក្នុងការកើតឡើង ឬរីករាលដាលនៃការខូចខាតតុលាការអាចគិតពិចារណានូវកំរិតនៃការរួមចំណែកនោះនៅពេលធ្វើការគណនាចំនួនទឹកប្រាក់នៃសំណងការខូចខាត ។[61]

នៅក្នុងស្ថានភាពខ្លះការខូចខាត ឬការរីករាលដាលនៃការខូចខាតបានកើតឡើងដោយមានការចូលរួមពីសំណាក់ជនរងគ្រោះផ្ទាល់ ឬរបស់អ្នកមានករណីយកិច្ចត្រួតពិនិត្យអ្នករងគ្រោះពោលគឺកំហុសរបស់

---

[59] ក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧, មាត្រា ៧៦៣។

[60] សេចក្តីពន្យល់ក្រមរដ្ឋប្បវេណី, (ភ្នំពេញ៖សាលាភូមិន្ទរដ្ឋបាល,២០១២) ភាគ៤, ទំព័រ៣៧។

[61] ក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧, មាត្រា ៧៦៤។

ជនរងគ្រោះ ឬកំហុសរបស់អ្នកមានករណីយកិច្ចត្រួតពិនិត្យអ្នករងគ្រោះដោយអំពើធ្វេសប្រហែស ខ្ជីខ្ជា ឬមិនបានប្រុងប្រយ័ត្ន។

ក្នុងករណីនេះនៅពេលគណនាអំពីចំនួនទឹកប្រាក់នៃការខូចខាតនោះតុលាការត្រូវ គិតពិចារណានូវកម្រិតនៃការរួមចំណែករបស់ជនរងគ្រោះ ឬអ្នកមានករណីយកិច្ចត្រួតពិនិត្យជនរងគ្រោះដើម្បីកាត់បន្ថយនូវសំណងនៃការខូចខាតសម្រាប់ជនដែលបានប្រព្រឹត្តនូវអំពើអនីត្យានុកូល និងដើម្បីថានានូវគោលការណ៍សមភាពផងដែរ ។[62]

## ៣.៤. អាជ្ញាយុកាលនៃការរំលត់សិទ្ធិទាមទារ

យោងតាមមាត្រា៧៦៥ នៃក្រមរដ្ឋប្បវេណី សិទ្ធិទាមទារសំណងនៃការខូចខាតដោយអំពើអនីត្យានុកូលត្រូវរលត់ដោយអាជ្ញាយុកាល :

- អំឡុងពេល៣ឆ្នាំ បានកន្លងហួស បន្ទាប់ពីពេលដែលជនរងគ្រោះ ឬអ្នកតំណាងដែលច្បាប់បានកំណត់របស់ជនរងគ្រោះនោះបានដឹងថា អាចទាមទារសំណង ការខូចខាតចំពោះអ្នកប្រព្រឹត្តអំពើបំពាន
- អំឡុងពេល១០ឆ្នាំបានកន្លងហួស បន្ទាប់ពីអំពើអនីត្យានុកូលនោះត្រូវបានប្រព្រឹត្ត។

អាជ្ញាយុកាលនៃការរំលត់សិទ្ធិទាមទារ សំដៅលើការរលត់សិទ្ធិទាមទារ សំណង ខូចខាតដោយផ្អែកលើការមិនបានប្រើប្រាស់សិទ្ធិទាមទាររបស់ជនរងគ្រោះក្នុងរយៈពេលដែលច្បាប់កំណត់ ។[63]

[62] ឯកឧត្តម ហ៊ី សោភា, មេរៀនស្តីពីអំពើអនីត្យានុកូល, ទំព័រ ៨១។

[63] កិច្ចប្រជុំក្រុមការងារជម្រុះលើកទី៣(សាលប្រជុំក្រសួងយុត្តិធម៌៖ ធ្នូ ២០១៥), ទំព័រ ១៤។

# សេចក្ដីសន្និដ្ឋាន

# សេចក្តីសន្និដ្ឋាន

ដោយឆ្លងកាត់ការបកស្រាយខាងលើនៃប្រធានបទស្តីពី **ការទទួលខុសត្រូវចំពោះត្រូវអំពើអនីត្យានុកូលរបស់ដទៃ** អស់រយៈពេលកន្លងមក បានបង្ហាញឱ្យឃើញថា ការជ្រើសយកប្រធានបទមកបកស្រាយ គឺសមស្របទៅនឹងបរិបទសង្គមនាពេលបច្ចុប្បន្នដែលអំពើអនីត្យានុកូលនេះ គឺកើតមានជារៀងរាល់ថ្ងៃនៅក្នុងប្រទេសកម្ពុជាយើង ក៏ដូចជាបណ្តាប្រទេសផ្សេងៗទៀតដែរ។ ដើម្បីឱ្យសង្គមជាតិមួយមានការរីកចម្រើន មានសណ្តាប់ធ្នាប់ល្អ សន្តិសុខ រដ្ឋាភិបាលបានខិតខំបង្កើតនូវវិធានច្បាប់ សម្រាប់គ្រប់គ្រងនៅក្នុងការរស់នៅរបស់មនុស្ស ដែលតម្រូវឱ្យមនុស្សម្នាក់ៗមានការទទួលខុសត្រូវនូវអំពើរបស់ខ្លួន។ ទោះបីជននោះប្រព្រឹត្តកំហុសដោយចេតនា ឬអចេតនាក៏មិនអាចរួចផុតពីការទទួលខុសត្រូវដែល។

ម្យ៉ាងទៀតក្នុងការសិក្សាស្រាវជ្រាវប្រធានបទមួយនេះបានលើកពីការទទួលខុសត្រូវនូវអំពើរបស់អ្នកដទៃ។ ការទទួលខុសត្រូវមិនត្រឹមតែលើការខូចខាត ដែលបុគ្គលណាម្នាក់បានប្រព្រឹត្តដោយកំហុសផ្ទាល់ទេ ប៉ុន្តែបុគ្គលនោះក៏ត្រូវទទួលខុសត្រូវទៅនឹងអំពើទាំងឡាយរបស់បុគ្គល ដែលស្ថិតនៅក្រោមការគ្រប់គ្រងមើលថែរក្សារបស់បុគ្គលនោះផងដែរ។ ការទទួលខុសត្រូវអំពើរបស់អ្នកដទៃ ទោះបីជាបុគ្គលនោះមិនបានប្រព្រឹត្តកំហុសនោះក៏ដោយ ក៏បុគ្គលនោះត្រូវទទួលខុសត្រូវអំពើរបស់បុគ្គលដែលមានចំណងគតិយុត្តជាមួយខ្លួន។ ការទទួលខុសត្រូវអំពើអ្នកដទៃមានដូចជា ការទទួលខុសត្រូវរបស់អ្នកត្រួតពិនិត្យ ការទទួលខុសត្រូវរបស់និយោជក ការទទួលខុសត្រូវអំពើអនីត្យានុកូលរបស់មន្ត្រីរាជការ និងការទទួលខុសត្រូវរបស់នីតិបុគ្គល។ ការទទួលខុសត្រូវរបស់អ្នកត្រួតពិនិត្យ ជាការទទួលខុសត្រូវរបស់បុគ្គលដែលមានករណីត្រួតពិនិត្យចំពោះអំពើអនីត្យានុកូលរបស់បុគ្គលដែលស្ថិតក្រោមការគ្រប់គ្រងរបស់ខ្លួន។ ហើយការទទួលខុសត្រូវរបស់និយោជកគឺការទទួលខុសត្រូវរបស់និយោជកចំពោះកំហុសដែលកើតឡើងដោយសារតែនិយោជិត ដែលបានបំពេញការងារតាមបញ្ជារបស់និយោជក។ ម្យ៉ាងវិញទៀត ការទទួលខុសត្រូវរបស់មន្ត្រីរាជការ គឺរដ្ឋ ឬស្ថាប័នសាធារណៈត្រូវទទួលខុសត្រូវក្នុងការសងការខូចខាត ដែលមន្ត្រីរាជការដែលទទួលការអនុវត្តនូវអំណាចសាធារណៈរបស់រដ្ឋបានប្រព្រឹត្ត។ ចំណែកឯ ការទទួលខុសត្រូវរបស់នីតិបុគ្គល សំដៅដល់ការទទួលខុសត្រូវក្នុងការសងការខូចខាត បង្កឡើងដោយអភិបាល ឬអ្នកតំណាងឯទៀត។

សរុបសេចក្តីជារួមមក ការទទួលខុសត្រូវអំពើអនីត្យានុកូលរបស់អ្នកដទៃ ជាការទទួលខុសត្រូវអំពើអនីត្យានុកូលមួយដែលកំពុងតែកើតនៅក្នុងការជីវិតរស់នៅរបស់មនុស្សក្នុងសង្គមនាពេលបច្ចុប្បន្ន។ ដោយសារតែប្រជាជនមិនសូវការយល់ដឹងអំពី ច្បាប់ សិទ្ធិ និងកាតព្វកិច្ច របស់ខ្លួន ទើបបង្កឱ្យការប្រព្រឹត្តអំពើអនីត្យានុកូលជាបន្តបន្ទាប់។

# អនុសាសន៍

# អនុសាសន៍

បន្ទាប់ពីបានធ្វើការសិក្សាស្រាវជ្រាវប្រធានបទរួចមក យើងខ្ញុំបានសង្កេតឃើញថា ការទទួលខុសត្រូវអំពើអំពើអនីត្យានុកូលរបស់អ្នកដទៃ មានការកើតឡើងជាប្រចាំក្នុងប្រទេសរបស់យើងនាពេលបច្ចុប្បន្ន។ ហើយអំពើអនីត្យានុកូលនេះ គឺបង្កនូវការខូចខាតដល់បុគ្គលដែលជនរងគ្រោះនៃអំពើនេះ។

ដូច្នេះហើយក្រោយពីបានធ្វើការសិក្សាស្រាវជ្រាវលើប្រធានបទនេះ តាមគំនិតយោបល់របស់នាងខ្ញុំទាំងពីរ ដើម្បីកាត់បន្ថយការកើនឡើងនៃអំពើអនីត្យានុកូលនេះត្រូវ៖

- រដ្ឋាភិបាលគួរតែបង្កើតឱ្យមាននូវបទបញ្ញត្តិច្បាប់ ឬការវិធានតឹងរឹងជាងនេះ ពាក់ព័ន្ធទៅនឹងការទទួលខុសត្រូវនូវអំពើអនីត្យានុកូល។
- បន្ថែមពីលើនេះ រដ្ឋាភិបាលគួរធ្វើការផ្សព្វផ្សាយ បណ្តុះបណ្តាល ឱ្យប្រជាជនបានយល់ដឹងកាន់តែច្បាស់អំពីអំពើអនីត្យានុកូល ការទទួលខុសត្រូវ និងការបង្កើនការប្រុងប្រយ័ត្នកុំឱ្យមានការធ្វើប្រព្រឹត្តនូវអំពើអនីត្យានុកូលនេះឡើង។
- លើសពីនេះ ប្រជាជនគួរតែធ្វើការស្វែងយល់អំពីអនីត្យានុកូល ផលប៉ះពាល់ដែលបង្កឡើងដោយអំពើអនីត្យានុកូល។ ប្រជាជនត្រូវមានការប្រុងប្រយ័ត្ន ជៀសវាងកុំឱ្យអំពើអនីត្យានុកូលកើតឡើងជាបន្តបន្ទាប់ទៀត។ម្យ៉ាងទៀត ប្រជាជនត្រូវរស់នៅទៅដោយប្រកបដោយសីលធម៌ គោរពសិទ្ធិគ្នាទៅវិញទៅមក ជៀសវាងនូវការប្រព្រឹត្តអំពើដែលប៉ះពាល់ដល់ប្រយោជន៍អ្នកដទៃ ដើម្បីកាត់បន្ថយអំពើអនីនុកូលនៅក្នុងសង្គម។

# ឯកសារយោង

# ឯកសារយោង

## ១. លិខិតបទដ្ឋានគតិយុត្ត


- ច្បាប់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា, ប្រកាសឱ្យប្រើនៅថ្ងៃទី២៤ កញ្ញា ១៩៩៣។
- ក្រមព្រហ្មទណ្ឌ, លេខ នស/រកម/១១០៩/០២២, ប្រកាសឱ្យប្រើនៅថ្ងៃទី៣០ វិច្ឆិកា ២០០៩។
- ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ប្រកាសឱ្យប្រើនៅថ្ងៃទី០៨ ធ្នូ ២០០៧។
- ច្បាប់ស្តីពីការងារ, លេខ ជស/រកម/០៣៩៧/០១, ប្រកាសឱ្យប្រើនៅថ្ងៃទី១០ មករា ១៩៩៧។


## ២. ឯកសារផ្សេងៗ


- វចនានុក្រមតម្រាច្បាប់
- សន្ទានុក្រមផ្នែករដ្ឋប្បវេណី ២០០៧
- សេចក្តីពន្យល់ក្រមរដ្ឋប្បវេណី, សាលាភូមិន្ទរដ្ឋបាល ភាគ៤, ២០១២
- សេចក្តីកំណត់ចំពោះមាត្រានីមួយៗនៃក្រមរដ្ឋប្បវេណី ភាគ៣, ក្រសួងយុត្តិធម៌,២០១០
- ឯកឧត្តម ហ៊ី សោភា,គ្មានកាលបរិច្ឆេទ, មេរៀនស្តីពីអំពើអនីត្យានុកូល
- សាស្ត្រាចារ្យ ញឹក វុធ្ធី, នីតិកាតព្វកិច្ចក្រៅកិច្ចសន្យា, ២០២៣
- កិច្ចប្រជុំក្រុមការងារជម្រះលើកទី៣, សាលប្រជុំក្រសួងយុត្តិធម៌, ២០១៥

# ឧបសម្ព័ន្ធ

# ក្រមរដ្ឋប្បវេណី

# ជំពូកទី ១៦

# អំពើអនីត្យានុកូល

# ក្រមរដ្ឋប្បវេណី

បុគ្គលដែលបានផ្តល់តាវកាលិកនោះ មិនអាចទាមទារឱ្យសងតាវកាលិកនោះ មកវិញបាន ឡើយ ។

២-បញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ មិនរារាំងការអនុវត្តសិទ្ធិទាមទារសំណង របស់បុគ្គលដែលបានផ្តល់តាវកាលិកនៃការសង ចំពោះកូនបំណុលឡើយ ។

**មាត្រា ៧៤១.–** ការផ្តល់តាវកាលិកដោយមូលហេតុខុសច្បាប់

នៅក្នុងជំពូកទី ១៥ (សេចក្តីចម្រើនដោយឥតហេតុ) នេះ ក្នុងករណីដែលការទាមទាររបស់បុគ្គលដែលត្រូវបានខូចខាតផលប្រយោជន៍ ចំពោះបុគ្គលដែលបានទទួលផលប្រយោជន៍នោះ ផ្ទុយនឹងរបៀបរៀបរយសាធារណៈ ឬ ទំនៀមទម្លាប់ល្អ ឬ ច្បាប់ដែលទាក់ទងទៅនឹងសណ្តាប់ធ្នាប់សាធារណៈ ការទាមទារឱ្យសងនោះ ពុំត្រូវបានអនុញ្ញាតឡើយ ។

## ជំពូកទី ១៦
## អំពើអនីត្យានុកូល

**មាត្រា ៧៤២.–** និយមន័យនៃកំហុសចេតនា និង អចេតនា

នៅក្នុងជំពូកទី ១៦ (អំពើអនីត្យានុកូល) នេះ អំពើដោយមានកំហុសចេតនា ឬ អចេតនា សំដៅទៅលើ អំពើដែលត្រូវនឹងចំណុចណាមួយខាងក្រោមនេះ :

ក-ធ្វើអំពើបំពានដោយព្យាករទុកជាមុនអំពីការកើតឡើងនៃលទ្ធផល ហើយដោយទទួលយកការកើតឡើងនៃលទ្ធផលនោះ ។

ខ-ធ្វើអំពើដែល បើតាមប្រក្រតី បុគ្គលដែលមានឋានៈនៃការងារ ឬ បទពិសោធន៍ស្មើគ្នានឹងអ្នកធ្វើអំពើនោះ អាចព្យាករទុកជាមុនអំពីការកើតឡើងនៃលទ្ធផលក៏ដោយ ក៏អ្នកធ្វើអំពើនោះនៅតែពុំបានព្យាករទុកជាមុនអំពីការកើតឡើងនៃលទ្ធផលនោះ ដោយសារការធ្វេសប្រហែសមិនប្រុងប្រយ័ត្ន ហើយទោះជាមានករណីយកិច្ចជៀសវាងនូវលទ្ធផលនោះក៏ដោយ ក៏នៅតែប្រព្រឹត្តផ្ទុយនឹងករណីយកិច្ចនោះ ។

**មាត្រា ៧៤៣.—** ល័ក្ខខ័ណ្ឌ និង ការទទួលខុសត្រូវក្នុងការបញ្ជាក់បង្ហាញនៃអំពើអនីត្យានុកូលទូទៅ

១-បុគ្គលដែលបំពានដោយខុសច្បាប់នូវសិទ្ធិ ឬ ផលប្រយោជន៍របស់ជនដទៃ ដោយកំហុសចេតនា ឬ ដោយកំហុសអចេតនា ត្រូវទទួលខុសត្រូវក្នុងការសងការខូចខាតដែលកើតឡើងដោយអំពើនោះ ។

២-បញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះករណីដែលការខូចខាតបានកើតឡើង ដោយសារមានករណីយកិច្ចធ្វើអំពើណាមួយ តែមិនបានធ្វើអំពើនោះ ។

៣-ចំពោះកំហុសចេតនា ឬ កំហុសអចេតនារបស់ចារីនេះ ទំនាក់ទំនងនៃហេតុផលរវាងអំពើរបស់អ្នកប្រព្រឹត្តអំពើបំពាន និង ការកើតឡើងនៃការខូចខាត និង ការខូចខាតដែលកើតមានឡើងលើជនរងគ្រោះ បុគ្គលដែលទាមទារសំណងការខូចខាតនោះ ត្រូវបញ្ជាក់បង្ហាញ លើកលែងតែមានបញ្ញត្តិពិសេសនៅក្នុងក្រមនេះ ឬ ច្បាប់ផ្សេងទៀត ។

**មាត្រា ៧៤៤.—** សំណងនៃការខូចខាតដែលមិនមែនជាទ្រព្យសម្បត្តិ

បុគ្គលដែលទទួលខុសត្រូវតាមបញ្ញត្តិនៃមាត្រា ៧៤៣ (ល័ក្ខខ័ណ្ឌ និង ការទទួលខុសត្រូវក្នុងការបញ្ជាក់បង្ហាញនៃអំពើអនីត្យានុកូលទូទៅ) ខាងលើនេះ ត្រូវសងការខូចខាតចំពោះអ្វីដែលមិនមែនជាទ្រព្យសម្បត្តិផងដែរ ។

**មាត្រា ៧៤៥.—** អសមត្ថភាពក្នុងការទទួលខុសត្រូវ

១-ជនដែលមានអាយុក្រោម ១៤ (ដប់បួន) ឆ្នាំ មិនត្រូវទទួលខុសត្រូវចំពោះអំពើអនីត្យានុកូលទេ ។

២-បុគ្គលដែលស្ថិតក្នុងស្ថានភាពដែលមិនអាចយល់ដឹង និង វិនិច្ឆ័យបានអំពីការទទួលខុសត្រូវចំពោះអំពើរបស់ខ្លួន នៅពេលដែលខ្លួនបានប្រព្រឹត្តអំពើបំពាននោះ ដោយសារមានវិបត្តិផ្នែកបញ្ញាស្មារតី ឬ មូលហេតុផ្សេងទៀត មិនត្រូវទទួលខុសត្រូវចំពោះអំពើអនីត្យានុកូលឡើយ ។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីដែលស្ថានភាពនោះបណ្ដាលមក ដោយកំហុសចេតនា ឬ ដោយកំហុសអចេតនា ។

**មាត្រា ៧៤៦.–** ការទទួលខុសត្រូវរបស់អ្នកមានករណីយកិច្ចត្រួតពិនិត្យ

១-បុគ្គលដែលមានករណីយកិច្ចដែលបានកំណត់ដោយច្បាប់ក្នុងការត្រួតពិនិត្យអនីតិជនអាយុក្រោម ១៤ (ដប់បួន) ឆ្នាំ ឬ បុគ្គលដែលស្ថិតក្នុងស្ថានភាពដែលមិនអាចយល់ដឹង និង វិនិច្ឆ័យបានអំពីការទទួលខុសត្រូវចំពោះអំពើរបស់ខ្លួន ដោយសារមានវិបត្តិផ្នែកបញ្ញាស្មារតី ឬ មូលហេតុផ្សេងទៀត មានករណីយកិច្ចត្រូវសងការខូចខាតរបស់អ្នកដទៃ ដែលកើតឡើង ដោយអំពើបំពានរបស់បុគ្គលនៅក្រោមការត្រួតពិនិត្យរបស់ខ្លួននេះ ។

២-បុគ្គលដែលមានករណីយកិច្ចដែលបានកំណត់ដោយច្បាប់ក្នុងការត្រួតពិនិត្យអនីតិជនអាយុចាប់ពី ១៤ (ដប់បួន) ឆ្នាំ ឡើងទៅ ត្រូវទទួលខុសត្រូវដោយសាមគ្គីភាពជាមួយអនីតិជន ចំពោះការខូចខាតរបស់អ្នកដទៃដែលកើតឡើង ដោយអំពើអនីត្យានុកូលរបស់អនីតិជននោះ ។

៣-បុគ្គលដែលមានករណីយកិច្ចត្រួតពិនិត្យដែលទទួលខុសត្រូវក្នុងការសងការខូចខាត តាមបញ្ញត្តិនៃកថាខណ្ឌទី ២ ខាងលើនេះ អាចរួចខ្លួនពីការទទួលខុសត្រូវក្នុងការសងការខូចខាតបាន ដោយបញ្ជាក់បង្ហាញថា ខ្លួនបានបំពេញករណីយកិច្ចត្រួតពិនិត្យជាប្រក្រតី ។

**មាត្រា ៧៤៧.–** ការទទួលខុសត្រូវរបស់និយោជក

១-បុគ្គលដែលប្រើនិយោជិតដើម្បីអនុវត្តកិច្ចការ ត្រូវទទួលខុសត្រូវក្នុងការសងការខូចខាត ដែលនិយោជិតបានបង្កដល់អ្នកដទៃដោយខុសច្បាប់ ដោយកំហុសចេតនា ឬ ដោយកំហុសអចេតនា នៅក្នុងការអនុវត្តកិច្ចការនោះ ។

២-បុគ្គលដែលស្ថិតក្នុងឋានៈត្រូវត្រួតពិនិត្យនិយោជិតជំនួសនិយោជក ត្រូវទទួលខុសត្រូវដូចគ្នានឹងនិយោជកដែរ ។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីដែលបុគ្គលនោះបានត្រួតពិនិត្យដោយត្រឹមត្រូវ ។

៣-និយោជក ឬ អ្នកត្រួតពិនិត្យជំនួស អាចទាមទារសំណងពីនិយោជិតបានដោយយោងទៅតាមកម្រិតនៃកំហុសរបស់និយោជិតនោះ ។

**មាត្រា ៧៤៨.–** អំពើអនីត្យានុកូលរបស់នីតិបុគ្គល

១-នីតិបុគ្គលត្រូវទទួលខុសត្រូវក្នុងការសងការខូចខាត ដែលសមាជិកគណៈកម្មការនាយក ឬ អ្នកតំណាងឯទៀត បានបង្កដល់អ្នកដទៃដោយខុសច្បាប់ ដោយកំហុសចេតនា ឬ ដោយកំហុសអចេតនា ក្នុងការអនុវត្តភារកិច្ច ។

២-បើបានសងការខូចខាតតាមបញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ នីតិបុគ្គលអាចទាមទារសំណងពីអ្នកតំណាងដែលបានប្រព្រឹត្តអំពើបង្កការខូចខាតនោះ ។

**មាត្រា ៧៤៩.–** អំពើអនីត្យានុកូលរបស់មន្ត្រីរាជការ

១-បើមន្ត្រីរាជការដែលទទួលការអនុវត្តនូវអំណាចសាធារណៈរបស់រដ្ឋ ឬ ស្ថាប័នសាធារណៈ បានបង្កការខូចខាតដល់អ្នកដទៃដោយខុសច្បាប់ ដោយកំហុសចេតនា ឬ ដោយកំហុសអចេតនា ក្នុងការអនុវត្តភារកិច្ចរបស់ខ្លួននោះ រដ្ឋ ឬ ស្ថាប័នសាធារណៈត្រូវទទួលខុសត្រូវក្នុងការសងការខូចខាតនោះ ។

២-ក្នុងករណីដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ បើកម្រិតនៃការបំពានករណីយកិច្ចរបស់មន្ត្រីរាជការ ក្នុងការជៀសវាងនូវលទ្ធផល មានភាពធ្ងន់ធ្ងរ រដ្ឋ ឬ ស្ថាប័នសាធារណៈអាចទាមទារសំណងពីមន្ត្រីរាជការនោះបាន ។

**មាត្រា ៧៥០.–** ការទទួលខុសត្រូវរបស់អ្នកកាន់កាប់សត្វ

បុគ្គលដែលកាន់កាប់សត្វ ត្រូវទទួលខុសត្រូវក្នុងការសងការខូចខាតដែលកើតឡើងដល់អ្នកដទៃ ដោយសត្វដែលខ្លួនកាន់កាប់ ។

**មាត្រា ៧៥១.–** ការទទួលខុសត្រូវចំពោះផលិតផលរបស់អ្នកផលិតវត្ថុ

១-ក្នុងករណីដែលមានវិការៈនាំឱ្យមានគ្រោះថ្នាក់មិនសមហេតុផលក្នុងចលនវត្ថុដែលត្រូវបានផលិត ហើយបានបណ្តាល ឱ្យមានការខូចខាតដល់អ្នកដទៃដោយវិការៈនោះ ផលិតករនៃចលនវត្ថុនោះត្រូវទទួលខុសត្រូវក្នុងការសងនូវការខូចខាតនោះ ។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវអនុវត្តឡើយ ចំពោះករណីដែលមិនអាចប្រមាណនូវវិការៈនោះ តាមកម្រិតវិទ្យាសាស្ត្រ នៃបច្ចេកទេស ដែលមាននៅសម័យដែលផលិតនោះ ។

២-អ្នកដែលផលិតចលនវត្ថុដែលផ្សំដោយគ្រឿង ឬ វត្ថុធាតុដើមដែលមានវិការៈ ត្រូវទទួលខុសត្រូវក្នុងការសងនូវការខូចខាត ក្នុងនាមជាផលិតករផងដែរ ។

៣-ក្នុងខ្លឹមសារនៃមាត្រានេះ ចំពោះចលនវត្ថុដែលនាំចូល អ្នកនាំចូលត្រូវចាត់ទុកថាជាផលិតករ ។

៤-ក្នុងខ្លឹមសារនៃមាត្រានេះ បុគ្គលដែលបានដាក់សញ្ញាណនៃនាមករណ៍របស់ខ្លួនជាផលិតករ ឬ អ្នកលក់ នៅលើចលនវត្ថុ ត្រូវចាត់ទុកថាជាផលិតករនៃចលនវត្ថុនោះ ។

**មាត្រា ៧៥២.–** ការទទួលខុសត្រូវចំពោះវត្ថុគ្រោះថ្នាក់

បុគ្គលជាកម្មសិទ្ធិករ ឬ អ្នកគ្រប់គ្រងរថយន្ត គ្រឿងចក្រសម្រាប់ដឹកជញ្ជូនផ្សេងទៀត គ្រឿងផ្ទុះ វត្ថុធាតុវិទ្យុសកម្ម វត្ថុធាតុគីមីដែលមានជាតិពុល អតិសុខុមប្រាណឧត្បាត ឬ គ្រឿងដែលមានកម្រិតគ្រោះថ្នាក់ខ្ពស់ផ្សេងទៀត ត្រូវទទួលខុសត្រូវក្នុងការសងការខូចខាតដែលបង្កដល់អ្នកដទៃ ដោយសារវត្ថុគ្រោះថ្នាក់ដែលខ្លួនមានកម្មសិទ្ធិ ឬ គ្រប់គ្រង ។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីដែលការខូចខាតនោះកើតមានឡើងបណ្តាលមកពីប្រធានសក្តិ ឬ ករណីដែលការគ្រប់គ្រងវត្ថុគ្រោះថ្នាក់គ្មានវិការៈ ហើយការខូចខាតបានកើតឡើង ដោយសារអំពើរបស់ជនរងគ្រោះ ឬ តតិយជន ។

**មាត្រា ៧៥៣.–** ការទទួលខុសត្រូវចំពោះសំណង់ដែលជាប់នឹងដី

១-ក្នុងករណីដែលការសាងសង់សំណង់ដែលជាប់នឹងដី ឬ ការគ្រប់គ្រងសំណង់នោះ មានវិការៈ ហើយបានបណ្តាលឱ្យមានការខូចខាតដល់អ្នកដទៃ អ្នកគ្រប់គ្រងសំណង់ និង កម្មសិទ្ធិករនៃសំណង់នោះត្រូវទទួលខុសត្រូវដោយសាមគ្គីភាព ក្នុងការសងការខូចខាតនោះ ។ ប៉ុន្តែ ក្នុងករណីដែលអ្នកគ្រប់គ្រងបានបញ្ជាក់ថា ខ្លួនបានគ្រប់គ្រងដោយត្រឹមត្រូវ អ្នកគ្រប់គ្រងនោះអាចរួចផុតពីការទទួលខុសត្រូវបាន ។

២-បន្ទុករបស់កម្មសិទ្ធិករនៃសំណង់ដែលជាប់នឹងដី និង អ្នកគ្រប់គ្រងសំណង់នោះ ត្រូវកំណត់ទៅតាមកម្រិតនៃការបង្កឱ្យមានវិការៈ នៃការសាងសង់ ឬ ការគ្រប់គ្រង ។

**មាត្រា ៧៥៤.–** អំពើអនីត្យានុកូលរួម

១-បើការខូចខាតបានកើតឡើង ដោយសារអំពើរបស់បុគ្គលច្រើននាក់រួមគ្នា អ្នកប្រព្រឹត្តអំពើបំពាននីមួយៗត្រូវទទួលខុសត្រូវក្នុងការសងការខូចខាតដោយសាមគ្គីភាព ។

២-ក្នុងករណីដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ ប្រសិនបើអ្នកប្រព្រឹត្តអំពើបំពាននីមួយៗបានបញ្ជាក់អំពីភាគនៃអំពើដែលខ្លួនបានបង្កឱ្យមានការខូចខាត ជននោះត្រូវទទួលខុសត្រូវក្នុងការសងការខូចខាត តាមសមាមាត្រនៃភាគដែលខ្លួនបានបង្ក ។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីដែលទទួលស្គាល់ថាមានការសមគំនិត ឬ មានទំនាក់ទំនងសហការយ៉ាងជិតស្និទ្ធក្នុងចំណោមអ្នកប្រព្រឹត្តអំពើបំពាន ។

៣-បើជនម្នាក់ក្នុងចំណោមអ្នកប្រព្រឹត្តអំពើអនីត្យានុកូលរួម បានសងការខូចខាតទាំងអស់ ដោយចេញចំណាយរបស់ខ្លួន ជននោះអាចទាមទារសំណងពីអ្នកផ្សេងទៀតដែលប្រព្រឹត្តអំពើអនីត្យានុកូលរួមនោះបាន តាមសមាមាត្រនៃភាគដែលជនម្នាក់ៗបានបង្ក ។

**មាត្រា ៧៥៥.–** និយមន័យនៃការការពារជាធម្មានុរូប និង ស្ថានភាពចាំបាច់

១-អំពើការពារជាធម្មានុរូប សំដៅទៅលើអំពើវិលោភដែលពុំអាចជៀសវាងបានដើម្បីការពាររូបរាងកាយ ឬ ទ្រព្យសម្បត្តិរបស់ខ្លួន ឬ អ្នកដទៃ ចំពោះអំពើបំពានមិនត្រឹមត្រូវ ហើយដែលស្ថិតក្នុងករណីដែលពេលវេលានៃអំពើបំពាន និង អំពើវិលោភនោះ ស្ថិតជិតគ្នា និង មានតុល្យភាពរវាងវិធីការពារនិងកម្រិតនៃអំពើបំពាននោះ ។

២-អំពើដោយសារស្ថានភាពចាំបាច់ សំដៅទៅលើអំពើវិលោភដែលពុំអាចជៀសវាងបាន ដើម្បីការពាររូបរាងកាយ ឬ ទ្រព្យសម្បត្តិរបស់ខ្លួន ឬ អ្នកដទៃ ចំពោះគ្រោះថ្នាក់បច្ចុប្បន្ន ឬ អច្ចាសន្ន ហើយដែលស្ថិតក្នុងករណីមានតុល្យភាព រវាងវិធីការពារ និង កម្រិតគ្រោះថ្នាក់នោះ ។

**មាត្រា ៧៥៦.–** មូលហេតុនៃការរួចផុតពីភាពផ្ទុយច្បាប់

១-អ្នកប្រព្រឹត្តអំពើបំពានត្រូវរួចផុតពីការទទួលខុសត្រូវ ក្នុងករណីដែលមានការ

យល់ព្រម ឬ ការទទួលយកគ្រោះថ្នាក់ ពីសំណាក់អ្នករងគ្រោះ ។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីដែលការយល់ព្រម ឬ ការទទួលយកគ្រោះថ្នាក់នោះ មិនត្រូវបានសង្គមទទួលស្គាល់ថាសមហេតុផល ។

២-ចំពោះការខូចខាតដែលកើតមានឡើងដោយសារអំពើការពារជាធម្មានុរូប ឬ អំពើដោយសារស្ថានភាពចាំបាច់ អ្នកដែលបានប្រព្រឹត្តអំពើការពារ ឬ អំពើដោយសារស្ថានភាពចាំបាច់ ពុំត្រូវទទួលខុសត្រូវឡើយ ។ ក្នុងករណីនេះ បុគ្គលដែលបានប្រព្រឹត្តអំពើផ្ទុយច្បាប់ដែលជាមូលហេតុនៃអំពើនោះ ត្រូវទទួលខុសត្រូវ ។

៣-ចំពោះការខូចខាតដោយសារអំពើដែលត្រូវសង្គមទទួលស្គាល់ថា សមហេតុផល អ្នកប្រព្រឹត្តអំពើបំពានមិនត្រូវទទួលខុសត្រូវឡើយ ។

**មាត្រា ៧៥៧.-** គោលការណ៍សងការខូចខាតជាប្រាក់ និង ករណីលើកលែង

១-ជាគោលការណ៍ សំណងនៃការខូចខាតត្រូវសងជាប្រាក់ ។

២-ក្នុងករណីដែលមិនអាចទទួលការសង្គ្រោះត្រឹមត្រូវដោយសំណងជាប្រាក់ ជនរងគ្រោះអាចទាមទារឱ្យធ្វើបដិទាន ឬ អាចទាមទារឱ្យហាមឃាត់មិនឱ្យធ្វើអំពើណាមួយបាន ។

៣-ចំពោះការបរិហារកេរ្តិ៍ ក្រៅពីសំណងនៃការខូចខាត ជនរងគ្រោះអាចទាមទារវិធានការស្តារកិត្តិយសឡើងវិញ ដូចជាការផ្សព្វផ្សាយសេចក្តីសុំអភ័យទោសជាសាធារណៈបាន ។

**មាត្រា ៧៥៨.-** ការគណនាចំនួនទឹកប្រាក់នៃការខូចខាត

១-ក្នុងការគណនាចំនួនទឹកប្រាក់នៃការខូចខាតលើទ្រព្យសម្បត្តិដោយសារអំពើអនីត្យានុកូល ភាពខុសគ្នារវាងស្ថានភាពនៃទ្រព្យសម្បត្តិដែលត្រូវបានសន្មតថា នឹងមានប្រសិនបើគ្មានអំពើអនីត្យានុកូល និង ស្ថានភាពនៃទ្រព្យសម្បត្តិជាក់ស្តែង ក្រោយពេលដែលអំពើអនីត្យានុកូលបានកើតឡើង ត្រូវបានវាយតម្លៃ ដោយប្រើប្រាស់នូវស្ថិតិ និង ឯកសារផ្សេងទៀត ។

២-ក្នុងការគណនាចំនួនទឹកប្រាក់នៃការខូចខាតសតិអារម្មណ៍ដោយសារអំពើ

អនីត្យានុកូល ចំនួនទឹកប្រាក់នៃជម្ងឺចិត្ត ត្រូវបានវាយតម្លៃ ដោយគិតពិចារណានូវស្ថានភាពផ្សេងៗ ដូចជាកម្រិតនៃកំហុសចេតនា ឬ អចេតនារបស់អ្នកប្រព្រឹត្តអំពើបំពាន ប្រភេទ និង កម្រិតនៃការរងគ្រោះ អំពើរបស់អ្នកប្រព្រឹត្តអំពើបំពាននៅក្រោយអំពើបង្កឱ្យមានការរងគ្រោះនោះ ។

**មាត្រា ៧៥៩.–** ការទាមទារសំណងនៃការខូចខាតដោយសារការបាក់បែកវត្ថុ

នៅពេលដែលវត្ថុបានបាក់បែក ដោយអំពើអនីត្យានុកូល អ្នករងគ្រោះអាចទាមទារសំណង ដូចជាតម្លៃនៃវត្ថុដែលបាក់បែក ឬ សោហ៊ុយជួសជុលវត្ថុនោះ ជាអាទិ៍ ។

**មាត្រា ៧៦០.–** ការទាមទារសំណងនៃការខូចខាតដោយការបំពានលើជីវិត

១-បើជនរងគ្រោះទទួលមរណភាព ដោយអំពើអនីត្យានុកូល អ្នករងគ្រោះអាចទទួលសិទ្ធិទាមទារសំណងចំពោះការខូចខាតលើទ្រព្យសម្បត្តិ និង ការខូចខាតសតិអារម្មណ៍ ដែលបានកើតឡើងចំពោះខ្លួន រហូតដល់មរណភាព ។ ការខូចខាតលើទ្រព្យសម្បត្តិ ដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ នេះ ត្រូវរួមបញ្ចូលទាំងសោហ៊ុយព្យាបាល និង សោហ៊ុយចំណាយផ្សេងទៀតដែលជនរងគ្រោះបានបង់ ឬ មានករណីយកិច្ចត្រូវបង់ ចាប់ពីក្រោយអំពើបង្កឱ្យមានការរងគ្រោះ រហូតដល់ពេលទទួលមរណភាព ប្រាក់ចំណូលដែលជនរងគ្រោះមិនបានទទួល ចាប់ពីក្រោយអំពើបង្កឱ្យមានការរងគ្រោះ រហូតដល់ពេលទទួលមរណភាព ជាអាទិ៍ ។

២-បើបុគ្គលដែលមានករណីយកិច្ចផ្តល់អាហារកាតព្វកិច្ច ដោយច្បាប់ ទំនៀមទំលាប់ ឬ ដោយកិច្ចសន្យា បានទទួលមរណភាព ដោយអំពើអនីត្យានុកូល បុគ្គលដែលទទួលជីវព្រឹត្តិ អាចទាមទារសំណងការខូចខាតលើទ្រព្យសម្បត្តិ ដែលបានកើតឡើងចំពោះខ្លួន ដោយសារមរណភាពរបស់ជនរងគ្រោះ ។ ការខូចខាតលើទ្រព្យសម្បត្តិដែលបានកំណត់នៅក្នុងកថាខណ្ឌទី ២ នេះ ត្រូវរួមបញ្ចូលទាំងប្រាក់ជីវព្រឹត្តិដែលបុគ្គលដែលទទួលជីវព្រឹត្តិលែងបានទទួលដោយសារមរណភាពនៃជនរងគ្រោះ សោហ៊ុយដែលចេញជំនួសជនរងគ្រោះ សោហ៊ុយធ្វើបុណ្យសព ជាអាទិ៍ ។

៣-បើជនរងគ្រោះទទួលមរណភាព ដោយអំពើអនីត្យានុកូល សហព័ទ្ធ ញាតិនៅ

ក្នុង ១ (មួយ) ថ្នាក់ និង ញាតិដែលរស់នៅជាមួយជនរងគ្រោះ អាចទាមទារសំណង នៃការខូចខាតសតិអារម្មណ៍ដែលបានកើតឡើង ដោយសារមរណភាពរបស់ជនរងគ្រោះនោះបាន ។

**មាត្រា ៧៦១.–** ការទាមទារសំណងនៃការខូចខាតដោយការបំពានលើរូបរាងកាយ

បើមានការបំពានលើរូបរាងកាយ ដោយអំពើអនីត្យានុកូល ជនរងគ្រោះអាចទាមទារសំណងនៃការខូចខាតលើទ្រព្យសម្បត្តិ និង ការខូចខាតសតិអារម្មណ៍ដែលបានកើតឡើងចំពោះខ្លួន ។ ការខូចខាតលើទ្រព្យសម្បត្តិដែលបានកំណត់នៅក្នុងមាត្រានេះ ត្រូវរួមបញ្ចូលទាំងសោហ៊ុយព្យាបាលដែលបានចំណាយហើយ ឬ សោហ៊ុយព្យាបាលដែលប្រមាណថានឹងត្រូវចំណាយនាពេលអនាគត ប្រាក់ចំណូលដែលមិនអាចទទួលបាននៅពេលកំពុងព្យាបាល និង ប្រាក់ចំណូលដែលមិនអាចទទួលបាននៅពេលអនាគតដោយសារផលវិបាកដែលបន្សល់ក្រោយពីការព្យាបាល ជាអាទិ៍ ។ ការខូចខាតដែលបានកំណត់នៅក្នុងមាត្រានេះ ត្រូវរួមបញ្ចូលទាំងការឈឺចាប់ផ្នែកសតិអារម្មណ៍នៅពេលព្យាបាល និង ពេលអនាគត ជាអាទិ៍ ។

**មាត្រា ៧៦២.–** ការទាមទារសំណងនៃការខូចខាតផ្នែកសតិអារម្មណ៍ដោយសារការបរិហារកេរ្តិ៍

បើមានការបរិហារកេរ្តិ៍ ដោយអំពើអនីត្យានុកូល ជនរងគ្រោះអាចទាមទារសំណងនៃការខូចខាតសតិអារម្មណ៍ ដោយសារការអាប់ឱនកេរ្តិ៍ឈ្មោះក្នុងសង្គម ។

**មាត្រា ៧៦៣.–** ការទូទាត់ប្រាក់ចំណេញ និង ខាត

ប្រសិនបើជនរងគ្រោះបានទទួលផលចំណេញដោយសារអំពើអនីត្យានុកូល ចំនួនប្រាក់ចំណេញនោះត្រូវដកចេញ នៅពេលធ្វើការគណនាចំនួនទឹកប្រាក់នៃការខូចខាត ។

**មាត្រា ៧៦៤.–** ការទូទាត់នូវកំហុស

បើកំហុសរបស់ជនរងគ្រោះ ឬ កំហុសរបស់អ្នកដែលមានករណីយកិច្ចត្រូវត្រួតពិនិត្យជនរងគ្រោះ បានរួមចំណែកក្នុងការកើតឡើង ឬរីករាលដាលនៃការខូចខាត តុលាការ

អាចគិតពិចារណាទូវកម្រិតនៃការរួមចំណែកនោះ នៅពេលធ្វើការគណនាចំនួនទឹកប្រាក់នៃការខូចខាត ។

**មាត្រា ៧៦៥.–** អាជ្ញាយុកាលនៃការរំលត់

សិទ្ធិទាមទារសំណងនៃការខូចខាតដោយអំពើអនីត្យានុកូល ត្រូវរលត់ដោយអាជ្ញាយុកាល បើអំឡុងពេល ៣ (បី) ឆ្នាំ បានកន្លងហួស បន្ទាប់ពីពេលដែលជនរងគ្រោះ ឬ អ្នកតំណាងដែលច្បាប់បានកំណត់របស់ជនរងគ្រោះនោះ បានដឹងថា អាចទាមទារសំណងការខូចខាតចំពោះអ្នកប្រព្រឹត្តអំពើបំពាន ឬ បើអំឡុងពេល ១០ (ដប់) ឆ្នាំ បានកន្លងហួស បន្ទាប់ពីអំពើអនីត្យានុកូលនោះត្រូវបានប្រព្រឹត្តឡើង ។